# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

# គោលការណ៍ណែនាំ

# ស្តីពីការគ្រប់គ្រងទំនិញគ្រោះថ្នាក់

# នៅកំពង់ផែស្វយ័តភ្នំពេញ

រៀបចំដោយលោក **ទា វណ្ណារ៉េត**

## ខែតុលា ឆ្នាំ២០២០

# អក្សរកាត់និងពាក្យបំព្រួញ

| | |
|---|---|
| ក.ស.ភ. | កំពង់ផែស្វយ័តភ្នំពេញ |
| DG | Dangerous Goods ទំនិញគ្រោះថ្នាក់ |
| IMDG | International Maritime Dangerous Goods Code ក្រមទំនិញគ្រោះថ្នាក់តាមសមុទ្រអន្តរជាតិ |
| IMO | International Maritime Organization អង្គការនាវាចរណ៍សមុទ្រអន្តរជាតិ |
| LM | Lower Mekong ទន្លេមេគង្គក្រោម |
| SDS | Safety Data Sheet ឯកសារទិន្នន័យផ្ទៀងផ្ទាត់សុវត្ថិភាពសារធាតុគ្រោះថ្នាក់ |
| PG | Packing Group ក្រុមនៃការវេចខ្ចប់ |
| PPE | Personal Protective Equipment ឧបករណ៍ការពាររាងកាយ |
| SOLAS | The International Convention for the Safety of Life at Sea អនុសញ្ញាអន្តរជាតិស្តីពីសុវត្ថិភាពជីវិតមនុស្សនៅសមុទ្រ |
| TS | Tonle Sap ទន្លេសាប |
| TEU | Twenty-foot Equivalent Unit កុងតឺន័រមានខ្នាត២០ហ្វីត |
| UN | United Nations អង្គការសហប្រជាជាតិ (អ.ស.ប.) |
| UM | Upper Mekong ទន្លេមេគង្គលើ |

# មាតិកា

**អក្សរកាត់និងពាក្យបំព្រួញ** ........ iii
**មាតិកា** ........ iv
**សេចក្តីសង្ខេប** ........ vi
**និយមន័យ** ........ vii
**សេចក្តីថ្លែងអំណរគុណ** ........ ix
**១សេចក្តីផ្តើម** . ........ 1
១.១ ទិដ្ឋភាពទូទៅ ........ 1
១.២ ស្ថានភាពបច្ចុប្បន្នរបស់ចំណតផែកុងតឺន័រLM១៧ ........ 4
**២ គោលបំណង** ........ 5
**៣ វិសាលភាពនិងការអនុវត្ត** ........ 5
**៤វិធានទាក់ទងទៅនឹងទំនិញគ្រោះថ្នាក់** ........ 5
៤.១ ក្រមទំនិញគ្រោះថ្នាក់តាមសមុទ្រអន្តរជាតិ (IMDG Code) ........ 5
៤.២ ពិធីសារទី៩ស្តីពីទំនិញគ្រោះថ្នាក់ ........ 6
**៥ការគ្រប់គ្រងទំនិញគ្រោះថ្នាក់នៅកំពង់ផែស្វយ័តភ្នំពេញ** . ........ 7
៥.១ ការបែងចែកទំនិញគ្រោះថ្នាក់ ........ 7
៥.២ ការគ្រប់គ្រងទំនិញគ្រោះថ្នាក់ ........ 8
៥.២.១ សមាសភាព និងភារកិច្ចគ្រប់គ្រងទំនិញគ្រោះថ្នាក់របស់ ក.ស.ភ. ........ 8
៥.២.២ ទំនាក់ទំនងជាមួយ ក.ស.ភ. ........ 9
៥.២.៣ តួនាទីនិងភារកិច្ចរបស់អ្នកនាំទំនិញគ្រោះថ្នាក់នាំចូលឬនាំចេញ ........ 9
៥.២.៤ ការផ្តល់ពត៌មានអំពីទំនិញគ្រោះថ្នាក់ ........ 10
៥.២.៥ នីតិវិធីនាំចូល និងនាំចេញទំនិញគ្រោះថ្នាក់ ........ 11
៥.២.៦ នីតិវិធីប្រតិបត្តិការស្តង់ដារសម្រាប់ទំនិញគ្រោះថ្នាក់នៅកំពង់ផែស្វយ័តភ្នំពេញ ........ 14
៥.២.៧ តម្លៃសេវាកម្មនៅកំពង់ផែស្វយ័តភ្នំពេញសម្រាប់កុងតឺន័រផ្ទុកទំនិញគ្រោះថ្នាក់ ........ 15

**៦ការប្រុងប្រយ័ត្នទៅចំពោះការលើកដាក់ ដឹកជញ្ជូន និងរក្សាទុកទំនិញគ្រោះថ្នាក់**.........16
៦.១ ប្រតិបត្តិការលើកដាក់ ........ 16
៦.២ ការបិតស្លាកនិងសញ្ញាសម្គាល់នៅលើកញ្ចប់វេចខ្ចប់ ........ 16
៦.៣ ផ្លាកសញ្ញា Placards........ 18
៦.៤ ការទុកដាក់ទ្វារកុងតឺន័រផ្ទុកទំនិញគ្រោះថ្នាក់ចេញក្រៅ ........ 19
៦.៥ ការទុកដាក់ដាច់ដោយឡែកសម្រាប់កុងតឺន័រទំនិញគ្រោះថ្នាក់នៅលើទីលាន ........ 20
៦.៦ កម្រិតសីតុណ្ហភាពទាបបំផុតងាយឆាបឆេះ (Flash Point)........ 21
៦.៧ អាម៉ូញ៉ូមនីត្រាត (AMMONIUM NITRATE)........ 22
៦.៨ ការបណ្តុះបណ្តាលបុគ្គលិកក.ស.ភ........ 22
៦.៩ ផែនការឆ្លើយតបទៅនឹងគ្រោះអាសន្ននៅក.ស.ភ........ 22
**៧សន្និដ្ឋាន** ........ 23
**៨ឧបសម្ព័ន្ធ** . ........ 24
ឧបសម្ព័ន្ធទី១៖ ក្រុមទំនិញគ្រោះថ្នាក់តាមសមុទ្រអន្តរជាតិ ........ 24
ឧបសម្ព័ន្ធទី២៖ IMO Dangerous Goods Manifest ........ 30
ឧបសម្ព័ន្ធទី៣៖ ការគ្រប់គ្រងទូទៅចំពោះការរក្សាទុកនិងផ្ទេរផ្ទុកទំនិញគ្រោះថ្នាក់ ........ 31
ឧបសម្ព័ន្ធទី៤៖ សេចក្តីជូនដំណឹងស្តីពីការស្តុកទុកទំនិញគ្រោះថ្នាក់នៅចំណតផែកុងតឺន័រLM១៧ .... 34
ឧបសម្ព័ន្ធទី៥៖ វិធានការណ៍បង្ការ និងពន្លត់អគ្គិភ័យ ........ 36
ឧបសម្ព័ន្ធទី៦៖អនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០២០ ស្តីពីការដាក់ឱ្យ ប្រើប្រាស់បញ្ជីទំនិញហាមឃាត់ និងទំនិញជាប់កម្រិតកំណត់........ 42
**ឯកសារយោង** ........ 48

# សេចក្តីសង្ខេប

កំពង់ផែស្វយ័តភ្នំពេញស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងសាធារណការនិងដឹកជញ្ជូន និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។កំពង់ផែស្វយ័តភ្នំពេញមានចំណតផែចំនួន៧កន្លែងគឺៈ ចំណតផែរណបពហុបំណងទន្លេបិទ UM២ ចំណតផែរណបពហុបំណង UM១ ចំណតផែរណបពហុបំណងTS១១ ចំណតផែពហុបំណង TS៣ ចំណតផែអ្នកដំណើរ និងទេសចរ TS១ ចំណតផែកុងតឺន័រLM១៧ និងចំណតផែរណពហុបំណង LM២៦ ក្នុងចំណោមចំណតផែទាំងប្រាំពីរនេះ គឺមានតែចំណតផែកុងតឺន័រ LM១៧ មួយទេដែលមានសកម្មភាពមមាញឹកជាងគេក្នុងការលើកដាក់ទំនិញជាទូកុងតឺន័រ និងទំនិញរាយ រីឯចំណតផែដទៃទៀត គឺសម្រាប់បម្រើសេវាកម្មនាវាទេសចរណ៍ និងលើកដាក់ទំនិញរាយតែប៉ុណ្ណោះ។

យោងតាមការអនុវត្តជាក់ស្តែងកន្លងមកនេះ កំពង់ផែស្វយ័តភ្នំពេញបានទទួលទំនិញគ្រោះថ្នាក់នាំចូលតាមរយៈការដឹកជញ្ជូនតាមនាវាដែលផ្ទុកកុងតឺន័រទំនិញគ្រោះថ្នាក់ ដោយបានផ្ទេរពីនាវាមកទីលាននៃចំណតផែកុងតឺន័រ LM១៧ សម្រាប់ការរក្សាទុករយៈពេលខ្លី។

ដើម្បីទទួលបាននូវសុវត្ថិភាពនិងមានការទទួលខុសត្រូវខ្ពស់ ក្នុងការគ្រប់គ្រងទំនិញគ្រោះថ្នាក់នៅកំពង់ផែស្វយ័តភ្នំពេញ ចាំបាច់ត្រូវមានវិធានការក្នុងការរៀបចំនូវគោលការណ៍ណែនាំស្តីពីការគ្រប់គ្រងទំនិញគ្រោះថ្នាក់ ហើយកំពង់ផែស្វយ័តភ្នំពេញមានជំនឿយ៉ាងមុតមាំថា កម្មសិទ្ធិករនាវា អ្នកដឹកជញ្ជូន អ្នកជួលនាវា ម្ចាស់ទំនិញ ភ្នាក់ងារនាវា បុគ្គលិក ក.ស.ភ.ទាំងអស់ រួមទាំងសមត្ថកិច្ចពាក់ព័ន្ធផ្សេងទៀត នឹងចូលរួមសហការគ្នាក្នុងការអនុវត្តតាមគោលការណ៍ណែនាំស្តីពីការគ្រប់គ្រងទំនិញគ្រោះថ្នាក់នេះ ដើម្បីទប់ស្កាត់ហានិភ័យនានាដែលអាចបង្កឡើងដោយសារទំនិញគ្រោះថ្នាក់ ។

ថ្ងៃ ពុធ ៩រោច ខែ បុស្ស ឆ្នាំ ឆ្លូវ ត្រីស័ក ព.ស ២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០២២

**ប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជា**

**ប្រធានអគ្គនាយក**

**ហ៊ី បាវី**

## និយមន័យ

| | |
|---|---|
| **កំពង់ផែស្វយ័តភ្នំពេញ (ក.ស.ភ.)** | សំដៅលើក្រុមហ៊ុនរដ្ឋចុះបញ្ជីលក់មូលបត្រដែលមានទីស្នាក់ការកណ្ដាល ស្ថិតនៅអគារលេខ ៦៤៩ តិវិថីព្រះស៊ីសុវត្ថិ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ |
| **ទំនិញគ្រោះថ្នាក់** | សំដៅលើសារធាតុឬវត្ថុគ្រោះថ្នាក់ដូចមានចែងនៅក្នុងព្រះរាជក្រម នស/រកម/០១០៦/០០៥ ស្ដីពីការប្រកាសឱ្យប្រើច្បាប់ស្ដីពីការអនុម័តយល់ព្រមលើពិធីសារទី៩ ស្ដីពីទំនិញគ្រោះថ្នាក់ ដែលសារធាតុនិង វត្ថុទាំងនោះអាចបង្កអោយមានគ្រោះថ្នាក់ដល់មនុស្ស សត្វ បរិស្ថាន សុវត្ថិភាព នៅពេលដែលសារធាតុ ឬវត្ថុទាំងនោះត្រូវបានដឹកជញ្ជូន។ |
| **កម្មសិទ្ធិករនាវា** | សំដៅលើម្ចាស់ក្រុមហ៊ុន ឬនីតិបុគ្គល ក្នុងការប្រើប្រាស់នាវាសម្រាប់ការដឹកជញ្ជូនទំនិញ និងមានឈ្មោះនៅក្នុងឯកសារដឹកជញ្ជូន |
| **អ្នកជួលនាវា** | សំដៅលើអង្គការ និងនីតិបុគ្គលដែលបានចុះកិច្ចសន្យាជួលនាវាសម្រាប់ការដឹកជញ្ជូនទំនិញតាមផ្លូវទឹក |
| **ភ្នាក់ងារនាវា** | សំដៅលើភ្នាក់ងារឯកជនដែលបម្រើសេវាកម្មដល់នាវាជាតិនិងអន្តរជាតិដែលចេញចូលកំពង់ផែស្វយ័តភ្នំពេញ |
| **ម្ចាស់ទំនិញគ្រោះថ្នាក់** | សំដៅលើកម្មសិទ្ធិករទំនិញគ្រោះថ្នាក់ដែលមានឈ្មោះនៅក្នុងឯកសារដឹកជញ្ជូន |
| **អ្នកបញ្ជូនទំនិញគ្រោះថ្នាក់** | សំដៅលើអង្គការនិងនីតិបុគ្គលដែលមានឈ្មោះជាអ្នកបញ្ជូនទំនិញគ្រោះថ្នាក់នៅក្នុងឯកសារដឹកជញ្ជូន |
| **អ្នកទទួលទំនិញគ្រោះថ្នាក់** | សំដៅលើអង្គការនិងនីតិបុគ្គលដែលមានឈ្មោះជាអ្នកទទួលទំនិញគ្រោះថ្នាក់នៅក្នុងឯកសារដឹកជញ្ជូន |
| **លើកដាក់ឬផ្ទេរផ្ទុក** | សំដៅលើការលើកដាក់ ឬការផ្ទេរផ្ទុកទំនិញគ្រោះថ្នាក់ពីនាវាទៅទីលានកំណត់ផ្ទុកទំនិញគ្រោះថ្នាក់នៅចំណតផែក.ស.ភ. |

**ការរក្សាទុកទំនិញគ្រោះថ្នាក់** សំដៅលើការរក្សាទុកទំនិញគ្រោះថ្នាក់នៅលើទីលានរយៈពេលខ្លី ដែលបានកំណត់ដោយក.ស.ភ.

**ឈ្មោះផ្លូវការទំនិញគ្រោះថ្នាក់** សំដៅលើឈ្មោះផ្លូវការរបស់ទំនិញគ្រោះថ្នាក់ (Proper Shipping name ) ដូចបានចែងនៅក្នុងបញ្ជីនៃក្រម IMDG Code/ឬនៅក្នុងADR

**ស្លាក (Label)** យោងតាមក្រម IMDG Code សំដៅលើលេខវត្ថុដែលមានរូបភាពភ្ជាប់នៅលើកញ្ចប់ទំនិញគ្រោះថ្នាក់ដើម្បីកំណត់គ្រោះថ្នាក់នៃការដឹកជញ្ជូនទំនិញគ្រោះថ្នាក់ដែលមានទំហំ លក្ខណៈនិងពាក្យដូចដែលបានបញ្ជាក់នៅក្នុងការដឹកជញ្ជូនទំនិញគ្រោះថ្នាក់

**ស្លាកសញ្ញា (Placard)** យោងតាមក្រម IMDG Code សំដៅលើរបស់ដែលមានលេខវត្ថុនិងរូបភាពភ្ជាប់ជាមួយនៅផ្នែកខាងក្រៅកុងតឺន័រឬកញ្ចប់ ដើម្បីកំណត់គ្រោះថ្នាក់នៃការដឹកជញ្ជូនទំនិញគ្រោះថ្នាក់ដែលមាន ទំហំ លក្ខណៈ និងពាក្យដូចដែលបានបញ្ជាក់នៅក្នុងការដឹកជញ្ជូនទំនិញគ្រោះថ្នាក់

**សញ្ញាសម្គាល់ (Mark)** យោងតាមក្រម IMDG Code សំដៅលើរបស់ដែលមានឈ្មោះទំនិញគ្រោះថ្នាក់ត្រឹមត្រូវនិងមានលេខអង្គការសហប្រជាជាតិ (UN Number)ដោយរួមទាំងលេខវត្ថុ/រូបសញ្ញា ឬក៏ពាក្យផ្សេងទៀត លើកលែងតែមានការចែងនៅក្នុងស្លាកនិងផ្លាកសញ្ញាបិតភ្ជាប់នៅលើកញ្ចប់ ឬផ្នែកខាងក្រៅនៃកុងតឺន័រ ឬកញ្ចប់សម្រាប់ការប្រាប់ឱ្យដឹងជាមុននូវគ្រោះថ្នាក់នៃទំនិញគ្រោះថ្នាក់ទាំងនេះ។

# សេចក្តីថ្លែងអំណរគុណ

ក្នុងនាមជាអ្នករៀបចំ និងចងក្រងគោលការណ៍ណែនាំស្តីពីការគ្រប់គ្រងទំនិញគ្រោះថ្នាក់នៅកំពង់ផែស្វយ័តភ្នំពេញ ខ្ញុំបាទសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ **ឯកឧត្តម ហ៊ី ឋាវ** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកប្រធានអគ្គនាយកកំពង់ផែស្វយ័តភ្នំពេញ ដែលបានខិតខំខ្នះខ្នែងក្នុងការជម្រុញឱ្យមានការរៀបចំគោលការណ៍ណែនាំ ស្តីពីការគ្រប់គ្រងទំនិញគ្រោះថ្នាក់នៅកំពង់ផែស្វយ័តភ្នំពេញនេះឡើង ស្របតាមតម្រូវការចាំបាច់របស់កំពង់ផែស្វយ័តភ្នំពេញ តម្រូវការជាតិនិងអន្តរជាតិ ដើម្បីចៀសវាងនូវគ្រោះថ្នាក់ជាយថាហេតុនៅកំពង់ផែស្វយ័តភ្នំពេញ។

ខ្ញុំបាទក៏សូមថ្លែងអំណរគុណផងដែរចំពោះថ្នាក់ដឹកនាំ និងមន្ត្រីក.ស.ភ.ទាំងអស់ ដែលបានសហការ និងផ្តល់នូវអនុសាសន៍ល្អៗក្នុងការជួយកែលម្អគោលការណ៍ណែនាំនេះ ដូចមានសមាសភាពខាងក្រោមនេះ៖

| | |
|---|---|
| ១. **លោក យឹម ជឿន** | នាយកប្រតិបត្តិការចំណតផែកុងតឺន័រ LM១៧ |
| ២. **លោក គង់ ចាន់នី** | ប្រធានលេខាធិការដ្ឋាន |
| ៣. **លោក ហ៊ុន សុខាល័យ** | នាយកផែនការ/ទីផ្សារ |
| ៤. **លោក កៅ សុគុណ** | ប្រធានការិយាល័យសន្តិសុខប្រព័ន្ធ/CCTV |
| ៥. **លោក អៃ សំណាង** | ប្រធានការិយាល័យសុវត្ថិភាពសុខមាលភាព/បរិស្ថានផែ/ |
| ៦. **លោក អ៊ុង សុភ័ក្រ្ត** | ប្រធានអង្គភាពរៀបចំប្រតិបត្តិការចំណតផែកុងតឺន័រ LM១៧ |
| ៧. **លោកស្រី ជន មុនីរ័ត្ន** | ប្រធានស្តីទីការិយាល័យតម្លៃ/ទីផ្សារ |

**ទា ចន្ណារ៉េត**
**ប្រធានការិយាល័យកណ្តាធារ**

# ១. សេចក្តីផ្តើម

## ១.១ និដ្ឋភាពទូទៅ

កំពង់ផែស្វយ័តភ្នំពេញហៅកាត់ថា (ក.ស.ភ.) គឺស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ សហគ្រាសស្វយ័តនេះត្រូវបានបង្កើតឡើងដោយអនុក្រឹត្យលេខ ៥១ ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ១៩៩៨ និងយោងអនុក្រឹត្យ ០១ អនក្របក ចុះថ្ងៃទី៥ ខែមករា ឆ្នាំ២០០៩ ស្តីពីមណ្ឌលអាជីវកម្មកំពង់ផែស្វយ័តភ្នំពេញ ដែលត្រូវបានបែងចែកដូចខាងក្រោម៖

- មណ្ឌលអាជីវកម្មទន្លេសាប និងទន្លេបាសាក់ មានចម្ងាយ ៦គ.ម
- មណ្ឌលអាជីវកម្មទន្លេមេគង្គលើ មានចម្ងាយ ១០០គ.ម
- មណ្ឌលអាជីវកម្មទន្លេមេគង្គក្រោម មានចម្ងាយ ៦០គ.ម

សរុបចម្ងាយមណ្ឌលអាជីវកម្មកំពង់ផែស្វយ័តភ្នំពេញមាន ១៦៦គ.ម ហើយក្នុងនោះមានចំណតផែចំនួន ៧ កន្លែងគឺ៖ ចំណតផែរណបពហុបំណងទន្លេបិទ UM២ ចំណតផែរណបពហុបំណង UM១ ចំណតផែរណបពហុបំណងTS១១ ចំណតផែពហុបំណង TS៣ ចំណតផែអ្នកដំណើរ និងទេសចរ TS១ ចំណតផែកុងតឺន័រ LM១៧ និងចំណតផែរណពហុបំណង LM២៦។ ក្នុងចំណោមចំណតផែទាំងប្រាំពីរនេះ គឺមានតែចំណតផែកុងតឺន័រLM១៧មួយទេដែលមានសកម្មភាពមមាញឹកជាងគេក្នុងការលើកដាក់ទំនិញជាទូកុងតឺន័រ និងទំនិញរាយ រីឯចំណតផែផ្សេងៗទៀត គឺសម្រាប់បម្រើសេវាកម្មនាវាទេសចរណ៍ និងលើកដាក់ទំនិញរាយតែប៉ុណ្ណោះ។ ចំណតផែទាំង៧នោះរួមមាន៖

**១) ចំណតផែរណបពហុបំណងទន្លេបិទ UM២**

មានទីតាំងស្ថិតនៅភូមិទន្លេបិទ ឃុំទន្លេបិទ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ។ ចំណតផែនេះមានបម្រើសេវាកម្មលើកដាក់ទំនិញរាយ និងទំនិញជាកុងតឺន័រ ហើយមានសមត្ថភាពក្នុងការទទួលនាវាសមុទ្រដែលមានទម្ងន់ផ្ទុកសរុប រហូតដល់ ៤ ៥០០DWT។

**២) ចំណតផែរណបពហុបំណង UM១**

មានទីតាំងស្ថិតនៅផ្លូវជាតិលេខ ៦A ភូមិកណ្តាល ឃុំព្រែកអញ្ចាញ ស្រុកមុខកំពូល ខេត្តកណ្តាល។ ចំណតផែនេះមានបម្រើសេវាកម្មលើកដាក់ទំនិញចាក់ធារ ទំនិញរាយ និងទំនិញជាកុងតឺន័រ។

**៣) ចំណតផែរណបពហុបំណង TS១១**

មានទីតាំងស្ថិតនៅផ្លូវជាតិលេខ ៦A ភូមិកណ្តាល ឃុំព្រែកអញ្ចាញ ស្រុកមុខកំពូល ខេត្តកណ្តាល។

**៤) ចំណតផែពហុបំណង TS៣**

មានទីតាំងស្ថិតនៅផ្លូវលេខ២៦៩ តិរវិថីព្រះស៊ីសុវត្ថិ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ស្ថិតនៅចម្ងាយប្រមាណជា ២គីឡូម៉ែត្រពីចំណុចប្រសព្វទន្លេចតុមុខ ដែលជាកំពង់ផែទន្លេ សម្រាប់

បម្រើសេវាកម្មលើកដាក់ទំនិញរាយ និងប្រើប្រាស់ជាចំណតផែអ្នកដំណើរ និងទេសចរ។ ចំណតផែនេះមានប្រវែង៣០០ម៉ែត្រ និងទទឹង២០ម៉ែត្រ និងមានសមត្ថភាពអាចទទួលនាវាមានទម្ងន់សរុបចាប់ពី ៣ ០០០ DWT រហូតដល់ ៥ ០០០ DWT។

**៥) ចំណតផែអ្នកដំណើរ និងទេសចរ TS១**

មានទីតាំងស្ថិតនៅតិរវិថីព្រះស៊ីសុវត្ថិ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ។ ចំណតផែនេះ ជាចំណតបណ្តែតទឹក ដែលមានប៉ុងតុងប្រវែង៤៥ម៉ែត្រ និងទទឹង១៥ម៉ែត្រ ចំនួន២គ្រឿង និងប៉ុងតុង១គ្រឿងទៀតមានប្រវែង៣០ម៉ែត្រ និងទទឹង១២ម៉ែត្រ ជាចំណតផែសម្រាប់បម្រើសេវាកម្មនាវាទេសចរណ៍មានចំណុះសរុបរហូតដល់៣ ៥០០DWT។

**៦) ចំណតផែកុងតឺន័រ LM១៧**

មានទីតាំងស្ថិតនៅភូមិកណ្តាលលើ ឃុំបន្ទាយដែក ស្រុកកៀនស្វាយ ខេត្តកណ្តាល ដែលមានចំងាយតាមផ្លូវគោកប្រមាណជា ៣០គីឡូម៉ែត្រពីទិសអាគ្នេយ៍នៃទីក្រុងភ្នំពេញ។ ចំណតផែនេះបម្រើសេវាកម្មលើកដាក់ទំនិញជាកុងតឺន័រ ទំនិញរាយ និងមានសមត្ថភាពអាចទទួលនាវាមានទម្ងន់សរុបរហូតដល់ ៥ ០០០ DWT និងមានសមត្ថភាពផ្ទុកនៅលើទីលាន ៤០០ ០០០TEUs/ឆ្នាំ។

**៧) ចំណតផែរណបពហុបំណង LM២៦**

មានទីតាំងស្ថិតនៅភូមិកោះរកា ឃុំកោះរកា ស្រុកពាមជរ ខេត្តព្រៃវែង និងមានបម្រើសេវាកម្មលើកដាក់ទំនិញរាយ និងទំនិញជាកុងតឺន័រ។

# ផែនទីមណ្ឌលអាជីវកម្មកំពង់ផែស្វយ័តភ្នំពេញ



## ១.២ ស្ថានភាពបច្ចុប្បន្នរបស់ចំណតផែកុងតឺន័រLM១៧

ចំណតផែកុងតឺន័រLM១៧ គឺស្ថិតនៅក្រោមការគ្រប់គ្រងរបស់កំពង់ផែស្វយ័តភ្នំពេញ។ ចំណតផែនេះ មានទីតាំងស្ថិតនៅភូមិកណ្តាលលើ ឃុំបន្ទាយដែក ស្រុកកៀនស្វាយ ខេត្តកណ្តាល ដែលមានចំងាយប្រមាណជា ៣០គីឡូម៉ែត្រពីទិសអាគ្នេយ៍នៃទីក្រុងភ្នំពេញ។ ចំណតផែនេះបានចាប់ផ្តើមសាងសង់លើទំហំដីជាង១០ហិកតា ហើយបានចាប់ផ្តើមប្រតិបត្តិការចាប់តាំងពីដើមឆ្នាំ២០១៣ មកទល់នឹងបច្ចុប្បន្ន។




**គម្រោងរៀបចំទីលានដាក់ទំនិញគ្រោះថ្នាក់នៅចំណតផែកុងតឺន័រLM១៧**

ខាងក្រោមគឺជាបញ្ជីទំនិញគ្រោះថ្នាក់ឆ្លងកាត់តាមកំពង់ផែស្វយ័តភ្នំពេញក្នុងឆ្នាំ ២០១៧ ឆ្នាំ២០១៨ និងឆ្នាំ២០១៩។



## ២. គោលបំណង

គោលបំណងនៃគោលការណ៍ណែនាំស្ដីពីការគ្រប់គ្រងទំនិញគ្រោះថ្នាក់នេះ គឺដើម្បី៖

- បម្រើសេវាកម្មក្នុងការលើកដាក់ ដឹកជញ្ជូន និងរក្សាទុកទំនិញគ្រោះថ្នាក់នៅលើទីលានក្នុងរយៈពេលខ្លី
- ការពារបរិស្ថាន
- ធានាសុខមាលភាព
- ការពារសុវត្ថិភាព

## ៣. វិសាលភាពនិងការអនុវត្ត

គោលការណ៍ណែនាំស្ដីពីការគ្រប់គ្រងទំនិញគ្រោះថ្នាក់នេះ មានវិសាលភាពអនុវត្ត៖

- ចំណតផែទាំងអស់ដែលស្ថិតក្រោមការគ្រប់គ្រងរបស់ ក.ស.ភ.
- ទំនិញគ្រោះថ្នាក់ សារធាតុគ្រោះថ្នាក់ សម្ភារនិង/ឬវត្ថុគ្រោះថ្នាក់ដូចមានចែងនៅក្នុងក្រម IMDG Code (១៩៦០) រួមទាំងវិសោធនកម្ម។

## ៤. ចំណាត់ថ្នាក់ទំនិញគ្រោះថ្នាក់

### ៤.១. ក្រមទំនិញគ្រោះថ្នាក់តាមសមុទ្រអន្តរជាតិ (IMDG Code)

ក្រមទំនិញគ្រោះថ្នាក់តាមសមុទ្រអន្តរជាតិ IMDG Code (ឧបសម្ព័ន្ធទី១) បានបង្កើតឡើងចាប់តាំងពីឆ្នាំ១៩៦០ ក្នុងសន្និសីទស្ដីពីសុវត្ថិភាពជីវិតមនុស្សនៅសមុទ្រ ដែលបានផ្ដល់ជាអនុសាសន៍ចំពោះរដ្ឋាភិបាលដែលត្រូវអនុម័តលើក្រមអន្តរជាតិដែលមានទម្រង់ដូចគ្នា សម្រាប់ការដឹកជញ្ជូនទំនិញគ្រោះថ្នាក់តាមសមុទ្រ ដើម្បីបំពេញតាមបទប្បញ្ញត្តិដែលមានក្នុងសន្ធិសញ្ញាអន្តរជាតិឆ្នាំ១៩៦០ ស្ដីពីសុវត្ថិភាពជីវិតមនុស្សនៅសមុទ្រហៅកាត់ថា (SOLAS)។ សេចក្ដីសម្រេច ដែលអនុម័តដោយសន្និសីទក្នុងឆ្នាំ១៩៦០ បានចែងថា សំណើនៃក្រមអន្តរជាតិនេះ ត្រូវគ្របដណ្ដប់លើការងារវេចខ្ចប់ ចរាចរណ៍កុងតឺន័រ និងការរក្សាទុកទំនិញគ្រោះថ្នាក់ ដោយផ្អែកតាមតម្រូវការនៃការទុកដាក់ដាច់ដោយឡែក នូវសារធាតុដែលមិនអាចនៅជាមួយគ្នាបាន។

ក្រុមការងាររបស់គណៈកម្មាធិការសុវត្ថិភាពនាវាចរណ៍សមុទ្ររបស់ IMO បានចាប់ផ្តើមរៀបចំក្រមនេះនៅឆ្នាំ១៩៦១ ដោយបានសហការយ៉ាងជិតស្និទ្ធជាមួយគណៈកម្មការជំនាញរបស់ អ.ស.ប អំពីទំនិញគ្រោះថ្នាក់ ដែលក្នុងរបាយការណ៍ឆ្នាំ១៩៥៦ បានដាក់ចេញនូវតម្រូវការអប្បបរមា សម្រាប់ការដឹកជញ្ជូនទំនិញគ្រោះថ្នាក់ តាមគ្រប់មធ្យោបាយដឹកជញ្ជូន។

IMDG CODE ត្រូវបានធ្វើបច្ចុប្បន្នភាពជារៀងរាល់ពីរឆ្នាំម្តង ដោយផ្អែកលើមូលដ្ឋានមួយចំនួនដូចជាការបញ្ចូលទំនិញគ្រោះថ្នាក់ប្រភេទថ្មី បច្ចេកវិទ្យាថ្មី និងវិធីធ្វើការបែបថ្មី ឬការផ្ទេរផ្ទុកទំនិញគ្រោះថ្នាក់ និងសុវត្ថិភាពទូទៅតាមរយៈបទពិសោធន៍កន្លងមក។

## ៤.២. ពិធីសារទី៩ ស្តីពីទំនិញគ្រោះថ្នាក់

យោងព្រះរាជក្រម នស/រកម/០១០៦/០០៥ ស្តីពីការប្រកាសឱ្យប្រើច្បាប់ស្តីពីការអនុម័តយល់ព្រមលើពិធីសារទី៩ ស្តីពីទំនិញគ្រោះថ្នាក់ដែលរដ្ឋសភាបានអនុម័ត កាលពីថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០០៥ នាសម័យប្រជុំសភាលើកទី៣ នីតិកាលទី៣ និងដែលព្រឹទ្ធសភាបានអនុម័តយល់ស្របលើទម្រង់និងគតិនៃច្បាប់ទាំងស្រុង កាលពីថ្ងៃទី ០៨ ខែធ្នូ ឆ្នាំ២០០៥ នាសម័យប្រជុំ ពេញអង្គលើកទី១០ នីតិកាលទី១ ក្នុងមាត្រាទី៣ នៃពិធីសារទី៩ បានចែងអំពីការចាត់ថ្នាក់នូវទំនិញគ្រោះថ្នាក់ដូចខាងក្រោម៖

**ចំណាត់ថ្នាក់១៖** គ្រឿងផ្ទុះ
**ចំណាត់ថ្នាក់២៖** ឧស្ម័ន
- ចំណាត់ថ្នាក់រង២.១៖ ឧស្ម័នងាយឆេះ
- ចំណាត់ថ្នាក់រង២.២៖ ឧស្ម័នដែលមិនអាចឆេះនិងពុំមានជាតិពុល
- ចំណាត់ថ្នាក់រង២.៣៖ ឧស្ម័នពុល

**ចំណាត់ថ្នាក់៣៖** វត្ថុរាវអាចឆេះ និងវត្ថុរាវដែលងាយនឹងផ្ទុះ
**ចំណាត់ថ្នាក់៤៖** វត្ថុរឹងអាចឆេះ
- ចំណាត់ថ្នាក់រង៤.១៖ វត្ថុរឹងងាយឆេះ
- ចំណាត់ថ្នាក់រង៤.២៖ សារធាតុដែលអាចមានចំហេះដោយឯកឯង
- ចំណាត់ថ្នាក់រង៤.៣៖ សារធាតុទាំងឡាយដែលមានប្រតិកម្មជាមួយទឹកអាចបញ្ចេញឧស្ម័នចំហេះ

**ចំណាត់ថ្នាក់៥៖** សារធាតុអុកស៊ីត និងសរីរាង្គពែរអុកស៊ីត
- ចំណាត់ថ្នាក់រង៥.១៖ សារធាតុអុកស៊ីត

ចំណាត់ថ្នាក់រង៥.២៖ សរីរាង្គពែរអុកស៊ីត

**ចំណាត់ថ្នាក់៦៖** សារធាតុពុល និងសារធាតុឆ្លង

ចំណាត់ថ្នាក់រង៦.១៖ សារធាតុពុល

ចំណាត់ថ្នាក់រង៦.២៖ សារធាតុឆ្លង

**ចំណាត់ថ្នាក់៧៖** គ្រឿងវិទ្យុសកម្ម

**ចំណាត់ថ្នាក់៨៖** សារធាតុដែលស៊ីឬកាត់(អាស៊ីត)

**ចំណាត់ថ្នាក់៩៖** សារធាតុនិងអង្គធាតុគ្រោះថ្នាក់ផ្សេងទៀត។

## ៥. ការគ្រប់គ្រងទំនិញគ្រោះថ្នាក់នៅកំពង់ផែស្វយ័តភ្នំពេញ

### ៥.១ ការបែងចែកទំនិញគ្រោះថ្នាក់

យោងពិធីសារទី៩ ដូចបានចែងក្នុងចំណុចទី២.២. ខាងលើ ក.ស.ភ.សូមធ្វើការបែងចែកទំនិញគ្រោះថ្នាក់ជា ៣ក្រុមគឺ៖

| ចំណាត់ថ្នាក់ទំនិញគ្រោះថ្នាក់នៅក.ស.ភ | **បរិយាយ** |
|---|---|
| ទំនិញគ្រោះថ្នាក់ក្រុមទី ១ (ក.ស.ភ.) | សំដៅលើទំនិញគ្រោះថ្នាក់ដែលមានហានិភ័យខ្ពស់បំផុត ហើយមិនត្រូវបានអនុញ្ញាតឱ្យមានការលើកដាក់ ឬធ្វើចលនាដឹកជញ្ជូនឬឆ្លងកាត់ឬមានការផ្ទេរផ្ទុកនៅក្នុងចំណតផែបានឡើយ។ ទំនិញគ្រោះថ្នាក់ទាំងនោះរួមមានទំនិញគ្រោះថ្នាក់ក្នុង**ចំណាត់ថ្នាក់៦.២ សារធាតុឆ្លង** និងទំនិញគ្រោះថ្នាក់ក្នុង**ចំណាត់ថ្នាក់៧ សារធាតុវិទ្យុសកម្ម** ។ |
| ទំនិញគ្រោះថ្នាក់ក្រុមទី ២ (ក.ស.ភ.) | សំដៅលើទំនិញគ្រោះថ្នាក់ដែលមានហានិភ័យខ្ពស់ ដែលត្រូវបានអនុញ្ញាតឱ្យលើកដាក់ពីនាវាទៅកាន់រថយន្តដឹកជញ្ជូនដោយផ្ទាល់នៅចំណតផែ ក៏ប៉ុន្តែមិនត្រូវបានអនុញ្ញាតឱ្យមានការស្តុកទុកនៅក្នុងទីលានផ្ទុកទំនិញគ្រោះថ្នាក់នៅក្នុងចំណតផែបានឡើយ។ ទំនិញគ្រោះថ្នាក់ទាំងនោះរួមមាននៅក្នុង **ចំណាត់ថ្នាក់ ១ គ្រឿងផ្ទុះ** និងទំនិញគ្រោះថ្នាក់ស្ថិតក្នុង**ចំណាត់ថ្នាក់ ២៣ ឧស្ម័នពុល.**។ |

| | |
|---|---|
| ទំនិញគ្រោះថ្នាក់ក្រុមទី៣ (ក.ស.ភ.) | សំដៅលើទំនិញគ្រោះថ្នាក់ដែលពុំមានការបញ្ជាក់នៅក្នុងក្រុមទី១ និងទី២ ខាងលើ និងត្រូវបានអនុញ្ញាតឱ្យមានការលើកដាក់ឬផ្ទេរផ្ទុកពីនាវាទៅរថយន្តរួចដឹកជញ្ជូនទៅកាន់ទីលានផ្ទុកទំនិញគ្រោះថ្នាក់ដែលបានកំណត់ទុកនៅចំណតផែ។ |

## ៥.២ ការគ្រប់គ្រងទំនិញគ្រោះថ្នាក់

### ៥.២.១. សមាសភាព និងភារកិច្ចគ្រប់គ្រងទំនិញគ្រោះថ្នាក់របស់ ក.ស.ភ.

ក្រុមការងារគ្រប់គ្រងទំនិញគ្រោះថ្នាក់របស់ ក.ស.ភ. មានសមាសភាព និងភារកិច្ចដូចតទៅ៖

- នាយកប្រតិបត្តិការមានភារកិច្ចគ្រប់គ្រងការងារទូទៅ រួមទាំងការត្រៀមលក្ខណៈឆ្លើយតបនឹងហានិភ័យ
- នាយកផែនការ/ទីផ្សារ មានភារកិច្ចទំនាក់ទំនងជាមួយភ្នាក់ងារនាវា ឬម្ចាស់ទំនិញគ្រោះថ្នាក់ក្នុងការនាំចូលឬនាំចេញ ការស្តុកទុកនៅលើទីលាននិងទូទាត់តម្លៃនៅពេលទំនិញគ្រោះថ្នាក់ត្រូវបានដឹកជញ្ជូនចូលឬចេញពីទីលានក.ស.ភ. ឬផ្ទុកនៅលើនាវា
- ប្រធានអង្គភាពរៀបវេនប្រតិបត្តិការចំណតផែ មានភារកិច្ចធ្វើការតាមដានព័ត៌មានអំពីទំនិញគ្រោះថ្នាក់ដែលទទួលបានពីភ្នាក់ងារនាវា ឬម្ចាស់ទំនិញសម្រាប់ការនាំចូលឬនាំចេញហើយត្រូវផ្តល់ព័ត៌មាននេះទៅកាន់អ្នកបញ្ជាគ្រឿងចក្រ និងរថយន្តដឹកជញ្ជូនឱ្យមានការប្រុងប្រយ័ត្ន និងរៀបចំទុកដាក់នៅទីតាំងដែលបានកំណត់ទុក ឬត្រូវដឹកជញ្ជូនតាមរថយន្តចេញភ្លាមៗពីចំណតផែ ឬត្រូវដឹកជញ្ជូនពីទីលានទៅផ្ទុកនៅលើនាវាសម្រាប់ការនាំចេញ និងសហការក្នុងការត្រៀមលក្ខណៈឆ្លើយតបនឹងហានិភ័យ
- ប្រធានអង្គភាពរៀបចំប្រតិបត្តិការចំណតផែមានភារកិច្ចធ្វើការតាមដានព័ត៌មានអំពីទំនិញគ្រោះថ្នាក់ដែលទទួលបានពីភ្នាក់ងារនាវាឬម្ចាស់ទំនិញហើយត្រូវផ្តល់ព័ត៌មាននេះទៅកាន់អ្នកប្រចាំការនៅលើទីលានឱ្យមានការប្រុងប្រយ័ត្ន និងរៀបចំទុកដាក់នៅទីតាំងដែលបានកំណត់ទុក និងចាំបាច់ត្រូវពិនិត្យទូកុងតឺន័រ ស្លាកសញ្ញាទំនិញគ្រោះថ្នាក់ដែលបានបិត និងសហការក្នុងការត្រៀមលក្ខណៈឆ្លើយតបនឹងហានិភ័យ
- ប្រធានការិយាល័យសន្តិសុខ/ប្រព័ន្ធCCTV មានភារកិច្ចត្រួតពិនិត្យ និងផ្តល់ព័ត៌មានអំពីទំនិញគ្រោះថ្នាក់ដែលនាំចូលឬនាំចេញដោយទទួលបានពីភ្នាក់ងារនាវាឬម្ចាស់ទំនិញហើយត្រូវធ្វើរបាយការណ៍នាំចូលឬនាំចេញប្រចាំខែ និងត្រៀមលក្ខណៈក្នុងការឆ្លើយតបទៅនឹងហានិភ័យ។

### ៥.២.២ ទំនាក់ទំនងជាមួយ ក.ស.ភ.

អតិថិជនទាំងអស់ដែលនាំចូល និងនាំចេញទំនិញគ្រោះថ្នាក់ឆ្លងកាត់កំពង់ផែស្វយ័តភ្នំពេញ អាចទំនាក់ទំនងមកក.ស.ភ. តាមរយៈអ៊ីម៉ែល និងលេខទូរស័ព្ទខាងក្រោម៖

| លរ | នាម និងគោត្តនាម | តួនាទី | អ៊ីម៉ែល | លេខទូរស័ព្ទ |
|---|---|---|---|---|
| ១ | លោក យឹម ជឿន | នាយកប្រតិបត្តិការចំណតផែកុងតឺន័រLM១៧ | y.choeurn@gmail.com | 010444044 |
| ២ | លោក ហ៊ុន សុខាល័យ | នាយកផែនការ/ទីផ្សារ | hun_lay@yahoo.com | 010444358 |
| ៣ | លោក កៅ សុគុណ | ប្រធានការិយាល័យសន្តិសុខ/ប្រព័ន្ធ CCTV | Kausokun@yahoo.com | 087676386 |
| ៤ | លោក អ៊ុង សុភ័ក្រ | ប្រធានអង្គភាពរៀបចំប្រតិបត្តិការ | ungsopheak@live.com | 010444697 |
| ៥ | លោក លឹម វឌ្ឍនា | ប្រធានអង្គភាពរៀបវេនប្រតិបត្តិការ | lvoitana@hotmail.com | 010444389 |

### ៥.២.៣ តួនាទីនិងភារកិច្ចរបស់អ្នកនាំទំនិញគ្រោះថ្នាក់នាំចូលឬនាំចេញ

ដើម្បីនាំទំនិញគ្រោះថ្នាក់ចូល ឬនាំចេញ ម្ចាស់ទំនិញ អ្នកបញ្ជូនទំនិញ ម្ចាស់នាវា ឬក្រុមហ៊ុនដឹកជញ្ជូន (Shipping Lines)មានភារកិច្ចដូចតទៅ៖

ក. ត្រូវមានលិខិតអនុញ្ញាតពីសមត្ថកិច្ចពាក់ព័ន្ធ (អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា និងមានការអនុញ្ញាតពីអគ្គស្នងការដ្ឋាននគរបាលជាតិនៃក្រសួងមហាផ្ទៃ និងក្រសួងការពារជាតិ ចំពោះសារធាតុរំសេវ និងគ្រឿងផ្ទុះឆេះ។

ខ. ត្រូវផ្តល់ព័ត៌មានជាលាយលក្ខណ៍អក្សរដោយបំពេញប្រតិវេទន៍ទំនិញគ្រោះថ្នាក់(Dangerous goods manifest) តាមទម្រង់ IMO FAL Form 7 (ឧបសម្ព័ន្ធទី២) ដោយមានការចុះហត្ថលេខានិងបោះត្រាពីបរិបាលនាវាសម្រាប់ការនាំចូល ឬសម្រាប់ការនាំចេញត្រូវមានចុះហត្ថលេខានិងឈ្មោះរបស់ក្រុមហ៊ុន ហើយបញ្ជូនព័ត៌មាននេះតាមរយៈសារអេឡិចត្រូនិករបស់ក.ស.ភ.dangerousgoods-ops@ppap.com.kh ក្នុងរយៈពេល ២៤ម៉ោងមុននាវាមកដល់ផែ។

គ. ចំពោះក្រុមហ៊ុនដែលមានបំណងនាំទំនិញគ្រោះថ្នាក់ចេញ ត្រូវមានអ្នកជំនាញការផ្នែកទំនិញគ្រោះថ្នាក់ក្នុងរៀបចំការវេចខ្ចប់ទំនិញគ្រោះថ្នាក់ទុកដាក់ក្នុងកុងតឺន័រ ស្របតាមក្រមអន្តរជាតិ IMDG Code។ ជាមួយគ្នានេះដែរ ក៏ត្រូវបញ្ជាក់ឱ្យបានច្បាស់លាស់អំពីឈ្មោះនិងអាសយដ្ឋានរបស់ក្រុមហ៊ុនដែលនាំចេញទំនិញគ្រោះថ្នាក់ ព្រមទាំងផ្តល់ឈ្មោះនិងអាសយដ្ឋានត្រឹមត្រូវរបស់ក្រុមហ៊ុនទទួលទំនិញគ្រោះថ្នាក់ ។

ឃ. ត្រូវផ្តល់ប្រតិវេទន៍ទំនិញគ្រោះថ្នាក់ (Dangerous goods manifest) សម្រាប់ការនាំចូលឬនាំចេញទៅកាន់នាយកប្រតិបត្តិការចំណតផែកុងតឺន័រ LM១៧ មុនពេលលើកដាក់ទំនិញគ្រោះថ្នាក់នៅកំពង់ផែស្វយ័តភ្នំពេញ ។

ង. ករណីពុំបានផ្តល់ព័ត៌មានជាលាយល័ក្ខណ៍អក្សរតាមការកំណត់ក្នុងចំណុច "ខ" ខាងលើទេនោះ ក.ស.ភមានសិទ្ធិបដិសេធមិនឱ្យទំនិញគ្រោះថ្នាក់នោះឆ្លងកាត់ផែ លើកលែងតែមានមូលហេតុសមស្រប និងរហូតដល់មានការបំពេញលក្ខខណ្ឌគ្រប់គ្រាន់ដែលតម្រូវដោយ ក.ស.ភ។

### ៥.២.៤ ការផ្តល់ពត៌មានអំពីទំនិញគ្រោះថ្នាក់

ចំពោះទំនិញគ្រោះថ្នាក់ដែលត្រូវនាំចូលឬនាំចេញត្រូវផ្តល់ព័ត៌មានលម្អិតដូចខាងក្រោម៖

១. ឈ្មោះផ្លូវការទំនិញគ្រោះថ្នាក់ដូចមានចែងនៅក្នុង IMDG Code (Proper Shipping Name)
២. ចំនួនកញ្ចប់ (Number of Packages)
៣. ទម្ងន់ទំនិញសុទ្ធ (Net Weight)
៤. ចំណាត់ថ្នាក់ និងលេខ UN (Class and UN N°)
៥. កម្រិតសីតុណ្ហភាពទាបបំផុតងាយឆាបឆេះ (Flash Point)
៦. ក្រុមវេចខ្ចប់ (Packaging Group)

៧. លេខទូកុងតឺន័រ ឈ្មោះនាវា និងលេខធ្វើដំណើររបស់នាវា (Container N°., Vessel's name and Voyage)

៨. ឈ្មោះអ្នកបញ្ជូនទំនិញ អាសយដ្ឋាន និងលេខទូរស័ព្ទ (Shipper's Name & Address & Telephone)

៩. ឈ្មោះ និងលេខទូរស័ព្ទរបស់អ្នកជំនាញការ ផ្នែកទំនិញគ្រោះថ្នាក់ក្នុងប្រទេសកម្ពុជាក្នុងករណីមានអាសន្ន (Name and telephone number of the experts contactable in Cambodia in case of emergency)

១០. សូមភ្ជាប់មកជាមួយនូវបញ្ជីសុវត្ថិភាព ឬឯកសារផ្សេងៗដែលបញ្ជាក់លម្អិតអំពីទំនិញគ្រោះថ្នាក់នីមួយៗ (To attached safety date sheet or other documents having details of each dangerous goods)

១១. សូមមើលឧបសម្ព័ន្ធទី១ ទី២ ទី៣ និងទី៤ និង ដែលមានភ្ជាប់មកជាមួយនេះ។

## ៥.២.៥ នីតិវិធីនាំចូល និងនាំចេញទំនិញគ្រោះថ្នាក់

ការនាំចូល និងនាំចេញទំនិញនៅកំពង់ស្វយ័តភ្នំពេញ ត្រូវបានអនុវត្ត ២៤ម៉ោង ជារៀងរាល់ថ្ងៃ ដែលស្ថិតនៅការគ្រប់គ្រងរបស់អង្គភាពរៀបចំប្រតិបត្តិការចំណតផែកុងតឺន័រ LM១៧។

### ក. ប្រតិបត្តិការនាំទំនិញចូល

ប្រតិបត្តិការនាំទំនិញចូល (Import Cargo) សំដៅលើប្រតិបត្តិការផ្ទេរទំនិញពីនាវា មកលើស្ពានផែ/រថយន្ត និងទៅដល់ទីលាន។

ប្រតិបត្តិការនាំទំនិញចូល ត្រូវអនុវត្តតាមនីតិវិធីដូចខាងក្រោម៖

១. ក្រុមហ៊ុននាវា (Barge Operator) ត្រូវ upload discharging list ចូលក្នុងប្រព័ន្ធ (Terminal Operation System = TOS) ១២ម៉ោងមុនពេលនាវាមកដល់ចំណតផែ

២. ក្រោយពីបានទទួលឯកសារពីនាវា (Stowage Plan/ Packing list/ Manifest) អង្គភាពរៀបចំប្រតិបត្តិការចំណតផែកុងតឺន័រLM១៧ ត្រូវរៀបចំប្លង់លើទីលានដែលគ្រប់គ្រងនៅក្នុងប្រព័ន្ធ TOS

៣. ចំពោះទំនិញវាយចាំបាច់ត្រូវតែមាន Original Packing list/ Bill of Lading និង Manifest

៤. គ្រប់ទំនិញនាំចូលទាំងអស់ត្រូវមានទម្ងន់ ស្របតាមការប្រកាសទម្ងន់ទំនិញជាលាយល័ក្ខណ៍អក្សរ

៥. អង្គភាពរៀបវេនប្រតិបត្តិការចំណតផែកុងតឺន័រLM១៧ ត្រូវកំណត់ចំណតនាវាដែលត្រូវចូលចត ត្រៀមគ្រឿងចក្រ រថយន្ត សម្ភារការពារសុវត្ថិភាពផ្ទាល់ខ្លួន និងកម្មករ។

៥. ក្រុមហ៊ុនដឹកជញ្ជូន (Shipping Lines) ត្រូវធ្វើការបញ្ជាកក់ Booking Delivery Orderតាមប្រព័ន្ធប្រតិបត្តិការចំណតផែ (TOS) ដោយភ្ជាប់ឯកសារដូចខាងក្រោម ដើម្បីឱ្យកស.ភ ទទួលបានពត៌មាន.ជាមុនៗពេលអតិថិជនមកយកទំនិញ។

- ប័ណ្ណសម្គាល់ទំនិញមកដល់ផែ (Bill of Lading /Delivery Order/ Goods Arrival Notice/ Packing list) (ភ្ជាប់ឯកសារនៅពេលធ្វើការបញ្ជាកក់នៅក្នុង Booking Delivery Order នៅក្នុងប្រព័ន្ធ TOS
- លិខិតផ្ទេរសិទ្ធិ (ក្នុងករណីជាតំណាងម្ចាស់ទំនិញ ត្រូវផ្តល់ឯកសារច្បាប់ដើមមក អង្គភាពវិក្កយបត្រ

៦. អង្គភាពវិក្កយបត្រពិនិត្យ និងផ្ទៀងផ្ទាត់ឯកសារ និងចេញវិក្កយបត្រគិតថ្លៃសេវាកម្មលើកដាក់ (Lift on and gate fee)។ ក្នុងករណីមានជាប់ស្តុក (Storage) ឬមានតម្រូវការលើកដាក់ស្កែន (LOLO scan) ឬមានតម្រូវការរើទំនិញចេញពីកុងតឺន័រ (Unstuffing) ឬកុងតឺន័រជាប្រភេទត្រជាក់ (Reefer Container) ត្រូវគិតថ្លៃសេវាបន្ថែម។

៧. អតិថិជនត្រូវធ្វើការទូទាត់លើវិក្កយបត្រនៅបញ្ជរធនាគារ ឬទូទាត់តាមប្រព័ន្ធអេឡិចត្រូនិក (E-payment) ។

៨. អតិថិជន ត្រូវយកប័ណ្ណបញ្ចេញទំនិញរបស់គយ មកជួបបុគ្គលិកអង្គភាពរៀបចំប្រតិបត្តិការចំណតផែកុងតឺន័រ LM១៧ (ផ្នែកទំនិញនាំចូល) ដើម្បីបញ្ចេញទំនិញតាមប្រព័ន្ធ TOS បន្ទាប់មកត្រូវព្រីនបង្កាន់ដៃដោះដូរសម្ភារ (Equipment Interchange Receipt =EIR )។

៩. អង្គភាពច្រកទ្វារ ត្រូវធ្វើការផ្ទៀងផ្ទាត់លេខកុងតឺន័រ លេខរថយន្ត ជាមួយបង្កាន់ដៃដោះដូរសម្ភារ EIR និង Gate out (កាត់ចេញពីប្រព័ន្ធ)។

## ខ. ប្រតិបត្តិការនាំទំនិញចេញ

ប្រតិបត្តិការនាំចេញ (Export Cargo) សំដៅលើប្រតិបត្តិការទទួលទំនិញពីច្រកទ្វារ ក.ស.ភ. មកដាក់ទីលាន និងដឹកជញ្ជូនទំនិញពីទីលានផ្ទុកចូលនាវា។

ប្រតិបត្តិការនាំទំនិញចេញ ត្រូវអនុវត្តតាមនីតិវិធីដូចខាងក្រោម៖

១. អតិថិជនត្រូវធ្វើការបញ្ជាកក់ជាដាច់ខាត (Booking Receipt Order and Trucks) ចូលក្នុងប្រព័ន្ធ TOS មុនពេលកុងតឺន័រ និងរថយន្តត្រូវបានដឹកជញ្ជូនចូលមកដល់មាត់ច្រកទ្វារក.ស.ភ. ។ ករណីអតិថិជន

ពុំបានធ្វើការបញ្ជាកក់ (Booking Receipt Order and Trucks) ជាមុនទេនោះ ក.ស.ភ. នឹងមិនអនុញ្ញាតឱ្យរថយន្តចូលក្នុងទីលានឡើយ។

២. អង្គភាពច្រកទ្វារ ក.ស.ភ. ត្រូវពិនិត្យផ្ទៀងផ្ទាត់លេខរថយន្ត និងលេខកុងតឺន័រ ក្នុងប្រព័ន្ធ TOS បន្ទាប់ពីពិនិត្យឃើញថាត្រឹមត្រូវហើយ ត្រូវអនុញ្ញាតឱ្យរថយន្តដឹកកុងតឺន័រចូល (Activate) ក្នុងប្រព័ន្ធTOS និងព្រីន Truck announcement ។

៣. អង្គភាពរៀបចំប្រតិបត្តិការចំណតផែ ត្រូវពិនិត្យប័ណ្ណផ្ទៀងផ្ទាត់ទម្ងន់ផ្ទុកទំនិញសរុប Verified Gross Mass (VGM) ជាមួយលេខកុងតឺន័រ ក្នុងករណីម្ចាស់ទំនិញពុំមាន VGM ដូចនេះ ទំនិញត្រូវចូលថ្លឹងជញ្ជីងនៅ ក.ស.ភ. ហើយរាល់ការចំណាយនៃការថ្លឹងជាបន្ទុករបស់ម្ចាស់ទំនិញ។

៤. អង្គភាពរៀបចំប្រតិបត្តិការចំណតផែកុងតឺន័រ LM១៧ ត្រូវពិនិត្យទ្រង់ទ្រាយខាងក្រៅរបស់កុងតឺន័រ (Condition of Container)។ ករណីកុងតឺន័រមានទ្រង់ទ្រាយមិនប្រក្រតី អង្គភាពរៀបចំប្រតិបត្តិការ ត្រូវធ្វើកំណត់ហេតុជាមួយម្ចាស់ទំនិញ មុនពេលលើកកុងតឺន័រពីរថយន្តដាក់លើទីលាន។ បន្ទាប់ពីពុំឃើញមានអ្វីប្លែក បុគ្គលិកអង្គភាពចំប្រតិបត្តិការត្រូវចេញបង្កាន់ដៃដោះដូរសម្ភារ (EIR ជាមួយនិងប្លង់ដាក់លើទីលាន។

៥. អតិថិជន ត្រូវរៀបចំឯកសារដាក់ជូនអង្គភាពវិក្កយបត្រ ដើម្បីបង់ថ្លៃសេវាកម្មលើកដាក់ (Lift off and gate fee) ដែលមានដូចជា Release Order ប្រតិវេទន៍គយ (Customs Declaration) និង VGM។

៦. ក្នុងករណីមានជាប់ស្តុក (Storage) ឬមានតម្រូវការលើកដាក់ស្កែន (LOLO scan) ឬមានតម្រូវការផ្ទុកទំនិញចូលកុងតឺន័រ(stuffing)ឬកុងតឺន័រជាប្រភេទត្រជាក់ (Reefer Container) ត្រូវគិតថ្លៃសេវាបន្ថែម។

៧. អតិថិជនត្រូវធ្វើការទូទាត់លើវិក្កយបត្រនៅបញ្ជរធនាគារ ឬទូទាត់តាមប្រព័ន្ធអេឡិចត្រូនិក (E-payment)។

## ៥.២.៦ នីតិវិធីប្រតិបត្តិការស្តង់ដារសម្រាប់ទំនិញគ្រោះថ្នាក់នៅកំពង់ផែស្វយ័តភ្នំពេញ

### ក  នីតិវិធីប្រកាសទំនិញគ្រោះថ្នាក់តាមអេឡិចត្រូនិក

- ក្រុមហ៊ុននាវាត្រូវផ្តល់ពត៌មានមក ក.ស.ភ តាមប្រព័ន្ធ TOS យ៉ាងតិច២៤ ម៉ោង មុនពេលនាវាមកដល់
- ការទទួលខុសត្រូវរបស់បរិបាលនាវា កម្មសិទ្ធិករទំនិញ អ្នកដឹកជញ្ជូន អ្នកជួលនាវា ឬភ្នាក់ងារ
- ផ្តល់ឯកសារពាក់ព័ន្ធ (ប្រសិនបើមានតម្រូវការ)

**ផ្ទៀងផ្ទាត់ឯកសារដោយមន្ត្រីប្រតិបត្តិការផ្នែកទំនិញគ្រោះថ្នាក់**

មិនយល់ព្រម

សុពលភាពទិន្នន័យ & ត្រូវធ្វើនិងផ្ដល់សារឡើងវិញ (ប្រសិនបើចាំបាច់

(ទំនិញគ្រោះថ្នាក់ដែលពុំមានការអនុញ្ញាត  គឺហាមដាច់ខាតក្នុងការផ្ទេរ ឬផ្ទុក

យល់ព្រម

**ទំនិញគ្រោះថ្នាក់ក្រុមទី១ (ក.ស.ភ.)**

មិនត្រូវបានអនុញ្ញាត

**ទំនិញគ្រោះថ្នាក់ក្រុមទី២ (ក.ស.ភ.)**

នាំចូល៖ ផ្ទេរចេញពីនាវាភ្លាម

នាំចេញ៖ ផ្ទុកចូលនាវាភ្លាម

**ទំនិញគ្រោះថ្នាក់ក្រុមទី៣ (ក.ស.ភ.)**

នាំចូល៖  អនុញ្ញាតឱ្យស្តុកបណ្តោះអាសន្ន

នាំចេញ៖ អនុញ្ញាតឱ្យស្តុកបណ្តោះអាសន្ន

បញ្ចប់ការងារ

**សម្រាប់ពត៌មានបន្ថែមសូមទាក់ទង**

លោក យឹម ជឿន ៖នាយកប្រតិបត្តិការចំណតផែកុងតឺន័រ LM១៧

ទូរស័ព្ទលេខ៖ ០១០ ៨៨៨ ០៨៨

អ៊ីម៉ែល ៖ y.choeurn@gmail.com / dangerousgoods-ops@ppap.com.kh

### ខ) វិធានការផ្សេងៗទប់ទល់ទៅនឹងគ្រោះអាសន្ន

១. ចំពោះទំនិញគ្រោះថ្នាក់ចំណាត់ថ្នាក់ទី២ និងចំណាត់ថ្នាក់ទី៣ (ក.ស.ភ.) ផ្នែកប្រតិបត្តិការត្រូវមានវិធានការប្រគល់ទទួលភ្លាមៗ ដោយយកចេញ ឬផ្ទុកចូលនាវា និង/ឬយកចេញពីទីលានក្នុងរយៈពេលខ្លីបន្ទាប់ពីលើកចេញពីនាវា ឬដាក់ចុះពីរថយន្តមកទីលាន។

២. អតិថិជន ឬអ្នកទទួលទំនិញ /អ្នកដឹកជញ្ជូន ឬភ្នាក់ងារ ត្រូវធ្វើសំណើសុំរក្សាទុកទំនិញគ្រោះថ្នាក់បណ្តោះអាសន្ន ដោយដាក់ជូន ក.ស.ភ. តាមរយៈអ៊ីម៉ែលៈ dangerousgoods-ops@ppap.com.kh មុនពេលទំនិញគ្រោះថ្នាក់មកដល់ចំណតផែ ក្នុងករណីមិនបានជូនដំណឹងមកដល់ក.ស.ភ. ឱ្យបានដឹងជាមុននោះ ម្ចាស់ទំនិញ និង/ឬក្រុមហ៊ុនដឹកជញ្ជូនត្រូវទទួលខុស ត្រូវដោយខ្លួនឯងនៅពេលមានឧបទ្ទវហេតុកើតឡើង។

៣. នៅពេល ក.ស.ភ. យល់ព្រមតាមសំណើរបស់អតិថិជន ក្នុងការរក្សាទុកជាបណ្តោះអាសន្ននូវទំនិញគ្រោះថ្នាក់សម្រាប់ការនាំចូល/នាំចេញហើយនោះ ក.ស.ភ. ត្រូវត្រៀមជានិច្ចនូវវិធានការ ដើម្បីរក្សាសុវត្ថិភាពទប់ទល់ទៅនឹងគ្រោះអាសន្នដែលមានដូចជាៈ

- ត្រៀមបុគ្គលិកសន្តិសុខសម្រាប់ការប្រយុទ្ធប្រឆាំងនឹងអគ្គិភ័យ និងសង្គ្រោះបន្ទាន់
- ត្រួតពិនិត្យប្រតិបត្តិការលើកដាក់ និងដឹកជញ្ជូន
- ដាក់កម្លាំងល្បាតនៅទីតាំងរក្សាទុកទំនិញគ្រោះថ្នាក់
- ហាមអ្នកគ្មានភារកិច្ចចេញចូលទីលានស្តុកទុកទំនិញគ្រោះថ្នាក់
- មិនត្រូវឱ្យមានការជក់បារី ឬមានភ្លើងឆេះនៅក្បែរទីលានស្តុកទំនិញគ្រោះថ្នាក់

## ៥.២.៧. តម្លៃសេវាកម្មរបស់កំពង់ផែស្វយ័តភ្នំពេញសម្រាប់កុងតឺន័រផ្ទុកទំនិញគ្រោះថ្នាក់

ក.ស.ភ. បានរៀបចំសេចក្តីជូនដំណឹងកាលពីថ្ងៃទី១ ខែកក្កដា ឆ្នាំ២០២១ ទៅក្រុមហ៊ុននាវាទាំងអស់អំពីកាតព្វកិច្ចជូនដំណឹង ឬព័ត៌មានជាមុនអំពីទំនិញគ្រោះថ្នាក់ដែលត្រូវបានចាត់ចំណាត់ថ្នាក់ក្នុង IMDG Code ជូនទៅនាយកដ្ឋានប្រតិបត្តិការចំណតផែកុងតឺន័រ LM១៧ និងការិយាល័យសន្តិសុខ/ប្រព័ន្ធ CCTV យ៉ាងតិចបំផុតរយៈពេល ២៤ ម៉ោងមុននាវាមកដល់ចំណតផែរបស់ ក.ស.ភ.។

ក្នុងករណីដែលក្រុមហ៊ុននាវាមានការធ្វេសប្រហែសពុំបានផ្តល់ព័ត៌មានជាមុន ឬផ្តល់ព័ត៌មានខុស ក.ស.ភ. នឹងធ្វើការគិតថ្លៃសេវាកម្មទ្វេដងនៃតារាងតម្លៃរបស់ ក.ស.ភ. ចំពោះសេវាកម្មទាំងអស់ដែល ក.ស.ភ. ផ្តល់ជូន ដោយគិតចាប់ពីពេលកុងតឺន័រផ្ទុកទំនិញគ្រោះថ្នាក់ដឹកជញ្ជូនមកដល់ ក.ស.ភ. រហូតដល់កុងតឺន័រត្រូវបានដឹកជញ្ជូនចេញពីទីលាន ក.ស.ភ. ដោយវិក្កយបត្រនៃការចំណាយនេះ គឺជាបន្ទុកចំណាយរបស់ក្រុមហ៊ុននាវា (Barge Operator) ។ សេចក្តីជូនដំណឹងនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២១ តទៅ។

## ៦.ការប្រុងប្រយ័ត្នទូទៅចំពោះការលើកដាក់ ដឹកជញ្ជូន និងរក្សាទុកទំនិញគ្រោះថ្នាក់

ដើម្បីកាត់បន្ថយគ្រោះថ្នាក់ជាយថាហេតុដោយសារការលើកដាក់ ដឹកជញ្ជូន ឬរក្សាទុកទំនិញ គ្រោះថ្នាក់នៅកំពង់ផែស្វយ័តភ្នំពេញ ប្រតិបត្តិករផែ កម្មសិទ្ធិករនាវា បរិបាលនាវា និងភ្នាក់ងារនាវាតម្រូវឱ្យមានការប្រុងប្រយ័ត្ន និងការស្វែងយល់ជាទូទៅនូវចំណុចសំខាន់ៗ ដូចមានចែងនៅក្នុងឧបសម្ព័ន្ធទី៣ នៃគោលការណ៍ណែនាំនេះ។ ក្រៅពីនេះប្រតិបត្តិករទាំងអស់ក៏ត្រូវយល់ដឹងនូវចំណុចមួយចំនួនបន្ថែមទៀតដូចខាងក្រោម៖

### ៦.១ ប្រតិបត្តិការលើកដាក់

នៅក្នុងពេលប្រតិបត្តិការលើកដាក់ទំនិញគ្រោះថ្នាក់ ប្រតិបត្តិករទាំងអស់ត្រូវមានសម្លៀកបំពាក់ការពាររាងកាយផ្ទាល់ខ្លួន (PPE)។




ក្នុងពេលលើកដាក់ឬផ្ទេរផ្ទុកទំនិញគ្រោះថ្នាក់នៅកំពង់ផែស្វយ័តភ្នំពេញ គឺហាមឃាត់ជាដាច់ខាតក្នុងការផ្ទេរផ្ទុកប្រេងទៅក្នុងនាវាឬគ្រឿងចក្រដែលនៅក្បែរ ។ ជាមួយគ្នានោះដែរ នាវាដែលនៅក្បែរត្រូវត្រៀមនាវិកសម្រាប់ការធ្វើចលនានាវា នៅពេលមានឧប្បត្តិហេតុកើតឡើង។

### ៦.២. ការបិតស្លាកនិងសញ្ញាសម្គាល់នៅលើកញ្ចប់វេចខ្ចប់

### ស្លាក និងសញ្ញាសម្គាល់

រាល់កញ្ចប់ទំនិញគ្រោះថ្នាក់ដែលត្រូវនាំចូល ឬនាំចេញតាមនាវាឆ្លងកាត់តាមកំពង់ផែស្វយ័តភ្នំពេញ ត្រូវមាន បិតស្លាក (Labeling) និងបិតសញ្ញាសម្គាល់ (Marking) ឈ្មោះផ្លូវការរបស់ទំនិញគ្រោះថ្នាក់(Proper Shipping Name) និងលេខ UN ដោយយោងតាម ក្រម IMDG Code ។







ស្លាកត្រូវបិតនៅលើ កេស ប្រអប់ រួមទាំង IBCs ផងដើម្បីបង្ហាញអំពីលក្ខណ:របស់ ទំនិញគ្រោះថ្នាក់ ដែលបានដឹកជញ្ជូន ។ ស្លាកត្រូវមានរង្វាស់ប្រវែងដូចខាងក្រោម៖ ១០០ មម x ១០០ មម ចំងាយរវាងខ្សែបន្ទាត់ព្រំខាងក្រៅ និងខ្សែបន្ទាត់ខាងក្នុង ៥ មម ។




**សញ្ញាសម្គាល់បំពុលបរិស្ថានសមុទ្រ** "Marine Pollutants"



## ស្លាកទិសដៅបញ្ឈរ

ស្លាកទិសដៅបញ្ឈរដែលត្រូវដាក់ ត្រូវបានបង្ហាញបន្ថែមជាមួយសញ្ញាបញ្ជាក់ទំនិញគ្រោះថ្នាក់ នៅលើឧបករណ៍វេចខ្ចប់ ជាមួយនឹងស្រទាប់ខាងក្នុង ដែលមានដាក់វត្ថុរាវនៃទំនិញគ្រោះថ្នាក់ ឬក៏ឧបករណ៍វេចខ្ចប់ ដែលមានមួយស្រទាប់ហើយមានក្បាលមូលសម្រាប់បិទបើក។ ស្លាកទិសដៅបញ្ឈរដែលត្រូវដាក់ប្រើសម្រាប់ជួយដល់អ្នកលើកដាក់ ឱ្យដឹងថាតើត្រូវលើកទុកដាក់ទំនិញនោះដោយរបៀបណា។ ទាំងនេះជារូបសញ្ញាព្រួញឡើងលើដាក់ឱ្យមើលឃើញបានយ៉ាងងាយ ប្រាប់ដល់អ្នកលើកដាក់ថាត្រូវដាក់បញ្ឈរឡើងលើ។




ស្លាកទិសដៅបញ្ឈរ

## ៦.៣. ផ្លាកសញ្ញា Placards

ផ្លាកសញ្ញា Placards ជាប្រភេទផ្លាកដែលបានពង្រីកធំ ប្រើសម្រាប់បិតផ្នែកខាងក្រៅនៃឧបករណ៍សម្រាប់ដឹកទំនិញគ្រោះថ្នាក់រួមមាន រថយន្តកុងតឺន័រ ស៊ីទែនប្រេង ជាដើម ដើម្បីប្រាប់ឱ្យដឹងថា ខាងក្នុងគឺមានវត្ថុធាតុគ្រោះថ្នាក់ ដែលបង្កហានិភ័យ (២៥០មម x ២៥០មម គំលាតរវាងខ្សែគែមខាងក្រៅ និងខ្សែខាងក្នុង១២.៥មម)។ ទំនិញគ្រោះថ្នាក់នៅក្នុងស៊ីទែន រឺឧបករណ៍ដាក់ទំនិញគ្រោះថ្នាក់ច្រើនជាង ៤០០០គីឡូក្រាម ដែលមានលេខ UN សំគាល់តែមួយ ហើយជាប្រភេទទំនិញគ្រោះថ្នាក់តែមួយគត់សម្រាប់ CTU នោះ រឺទំនិញគ្រោះថ្នាក់រឹងបែបចាក់ធារដែលដាក់ក្នុងកុងតឺន័រ ។

ចំពោះកុងតឺន័រដែលមានផ្ទុកទំនិញគ្រោះថ្នាក់ ត្រូវបិតផ្លាកសញ្ញា (Placarding) នៅខាងក្រៅកុងតឺន័រចំនួន ៤កន្លែង ស្របតាមបទដ្ឋាននៃក្រម IMDG Code និងត្រូវបិតនៅកន្លែងដែលងាយមើលឃើញច្បាស់។










ឧទាហរណ៍នៃការបិតផ្លាកសញ្ញាទំនិញគ្រោះថ្នាក់នៅលើកុងតឺន័រ

## ៦.៤ ការទុកដាក់ទ្វារកុងតឺន័រផ្ទុកទំនិញគ្រោះថ្នាក់ចេញក្រៅ




កុងតឺន័រទំនិញគ្រោះថ្នាក់នៅក្នុងរូបភាពខាងលើ គឺដាក់មិនត្រឹមត្រូវទេ ដោយសារផ្ទៃទ្វាររបស់កុងតឺន័រ គឺត្រូវបានបិតជិតក្នុងករណីមានគ្រោះអាសន្ន។ កុងតឺន័រមានទំនិញគ្រោះថ្នាក់នៃ (ចំណាត់ថ្នាក់ទី ៣ IMO Toluene UN 1294) ក្នុងករណីមានគ្រោះអាសន្ន យើងនឹងពុំអាចចូលទៅកាន់កុងតឺន័រនោះបានឡើយ។ដូចនេះ ទ្វារកុងតឺន័រនៃទំនិញគ្រោះថ្នាក់ ត្រូវតែដាក់បែរចេញមកក្រៅ ដើម្បីងាយស្រួលចូលទៅពេលមានគ្រោះអាសន្ន ។

## ៦.៥. ការទុកដាក់ដាច់ដោយឡែកសម្រាប់កុងតឺន័រទំនិញគ្រោះថ្នាក់នៅលើទីលាន

កុងតឺន័រផ្ទុកទំនិញគ្រោះថ្នាក់ដែលស្ថិតនៅក្នុងបរិវេណកំពង់ផែស្វយ័តភ្នំពេញ ចាំបាច់ត្រូវមានការទុកដាក់ដាច់ដោយឡែកតាមតារាងដូចខាងក្រោម៖

| CLASS OF DG | 2.1 | 2.2 | 2.3 | 3 | 4.1 | 4.2 | 4.3 | 5.1 | 5.2 | 6.1 | 8 | 9 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| 2.1 | 0 | 0 | 0 | | | | 0 | | | 0 | | 0 |
| 2.2 | 0 | 0 | 0 | | 0 | | 0 | 0 | | 0 | 0 | 0 |
| 2.3 | 0 | 0 | 0 | | 0 | | 0 | 0 | | 0 | 0 | 0 |
| 3 | | | | 0 | 0 | | | | | 0 | 0 | 0 |
| 4.1 | | 0 | 0 | 0 | 0 | | | | | 0 | | 0 |
| 4.2 | | | | | | 0 | | | | | | 0 |
| 4.3 | 0 | 0 | 0 | | 0 | | 0 | | | 0 | | 0 |
| 5.1 | | 0 | 0 | | | | | 0 | | | | 0 |
| 5.2 | | | | | | | | | 0 | | | 0 |
| 6.1 | 0 | 0 | 0 | 0 | 0 | | 0 | | | 0 | 0 | 0 |
| 8 | | 0 | 0 | 0 | | | | | | 0 | 0 | 0 |
| 9 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 |

| *IBC / TRAILER / FLAT RACK OR PLATFORM CONTAINERS* | |
|---|---|
| | ពុំចាំបាច់រំលែកចេញពីគ្នាទេ លុះត្រាតែមានកម្មវិធីថាឱ្យទុករៀងៗខ្លួន |
| | ដាក់ឱ្យឃ្លាតពីគ្នា ក្នុងចំងាយយ៉ាងតិច ៣ម៉ែត្រ |

| | |
|---|---|
| | ត្រូវរំលែកចេញពីគ្នា៖<br>→ យ៉ាងតិច ៦ម៉ែត្រ ក្នុងទីវាលលំហ ឱ្យស្របតាមលក្ខខណ្ឌនៃការរំលែកដាច់ពីគ្នា<br>→ យ៉ាងតិច ១២ម៉ែត្រ នៅក្នុងឃ្លាំង ឱ្យស្របតាមលក្ខខណ្ឌនៃការរំលែកដាច់ពីគ្នា ឬលុះត្រាតែមានជញ្ជាំងខ័ណ្ឌដាច់ពីភ្លើង |
| | ***CLOSED CONTAINERS / PORTABLE TANKS / CLOSED ROAD VEHICLES*** |
| | ពុំចាំបាច់រំលែកចេញពីគ្នាទេ |
| | ដាក់ឱ្យឃ្លាតពីគ្នា ឬពុំចាំបាច់រំលែកចេញពីគ្នាទេ Away from – no segregation necessary |
| | ត្រូវរំលែកចេញពីគ្នា៖<br>• នៅក្នុងទីវាលលំហ ត្រូវដាក់តាមបណ្ដោយ និងដាក់ទៅខាងៗ ក្នុងចំងាយយ៉ាងតិច ៣ម៉ែត្រ<br>• នៅក្នុងឃ្លាំងត្រូវដាក់តាមបណ្ដោយគ្នា និងដាក់ឱ្យទៅខាងៗ ក្នុងចំងាយយ៉ាងតិច ៦ម៉ែត្រដោយមានជញ្ជាំងដាក់ខ័ណ្ឌដាច់ពីភ្លើង |
| | ***OPEN ROAD VEHICLES / RAILWAY FREIGHT WAGONS / OPEN TOP CONTAINERS*** |
| | ពុំចាំបាច់រំលែកចេញពីគ្នាទេ |
| | ដាក់ឱ្យឃ្លាតពីគ្នា ក្នុងចំងាយយ៉ាងតិច ៣ម៉ែត្រ |
| | ដាក់ឱ្យឃ្លាតពីគ្នា៖<br>→ យ៉ាងតិច ៦ម៉ែត្រ ក្នុងទីវាលលំហដោយដាក់ តាមបណ្ដោយនិងដាក់ទៅខាងៗ ឱ្យស្របតាមលក្ខខណ្ឌនៃការរំលែកដាច់ពីគ្នា<br>→ យ៉ាងតិច ១២ម៉ែត្រ នៅក្នុងឃ្លាំងដោយដាក់ តាមបណ្ដោយ និងដាក់ទៅខាងៗ ឱ្យស្របតាមលក្ខខណ្ឌនៃការរំលែកដាច់ពីគ្នា ឬលុះត្រាតែមានជញ្ជាំងខ័ណ្ឌដាច់ពីភ្លើង |

## ៦.៦. កម្រិតសីតុណ្ហភាពទាបបំផុតងាយឆាបឆេះ ( Flash Point )

កម្រិតសីតុណ្ហភាពទាបបំផុតងាយឆាបឆេះ(Flash Point) ត្រូវបានកំណត់ថាជាសីតុណ្ហភាពអប្បបរមា ដែលផលិតផលប្រេងបញ្ចេញចំហាយឧស្ម័នគ្រប់គ្រាន់ បង្កជាទម្រង់ឆាបឆេះ នៅក្នុងលំហនៅផ្ទៃខាងលើរបស់ផលិតផលរាវនេះ។ ម្យ៉ាងវិញទៀត វាគឺជាសីតុណ្ហភាពអប្បបរមា ដែលចំហាយឧស្ម័នពីផលិតផលប្រេងចាប់ផ្ដើមឆាបឆេះ នៅពេលមានប្រភពជំរុញ ប៉ុន្តែមិនបន្តឆេះប្រសិនបើមិនមានការបន្តកើនកំដៅ។ កាលណាសីតុណ្ហភាពអប្បបរមានេះកាន់តែទាប នោះកម្រិតគ្រោះថ្នាក់កាន់តែខ្លាំង។ កម្រិតសីតុណ្ហភាពអប្បបរមាជាក់លាក់ អាចរកបាននៅក្នុងឯកសារ MSDS សម្រាប់ប្រភេទផលិតផលនីមួយៗ ។ ការវាយតំលៃហានិភ័យ ដោយប្រើកម្រិតសីតុណ្ហភាពអប្បបរមា និងផ្ដល់ព័ត៌មាន ដល់អ្នកដែលធ្វើការងារឆ្លើយតបករណីគ្រោះអាសន្ន ព្រោះបានដឹងអំពីហានិភ័យដែលមានសម្រាប់ ផលិតផលនីមួយៗ ។ នៅក្នុងលក្ខខណ្ឌជាក់ស្ដែង នេះបានន័យថា សីតុណ្ហភាពទាំងអស់ដែលលើសពី-៤៣ អង្សារសេ ផលិតផលប្រេងរាវ ចាប់ផ្ដើមបញ្ចេញចំហាយឧស្ម័ន ដែលអាចបណ្ដាលឱ្យឆាបឆេះ និងផ្ទុះ។

| ផលិតផលប្រេង | Flashpoint |
|---|---|
| ប្រេងម៉ាស៊ូត | > 52° C |
| ប្រេងសាំង | -43° C |
| ប្រេងកាត | 38° C - 41° C |
| ប្រេងយន្តហោះ | 38° C |

## ៦.៧. អាម៉ូញ៉ូមនីត្រាត (AMMONIUM NITRATE)

លក្ខខណ្ឌនៅក្នុងគោលការណ៍នេះ គឺអនុវត្តចំពោះអាម៉ូញូមនីត្រាត និងជីអាម៉ូញ៉ូមនីត្រាត ដែលមានក្នុងចំណាត់ថ្នាក់លេខ ៥.១. នៅក្នុងលេខកូដ IMDG (លេខ 2067, 3375, 2426 និង 1942) ដែលកន្លងមកទំនិញគ្រោះថ្នាក់ប្រភេទនេះ ត្រូវបាននាំចូលច្រើនជាងគេនៅកំពង់ផែស្វយ័តភ្នំពេញ។ Ammonium Nitrate គឺអាចឆាបឆេះ និងបង្កើននូវហានិភ័យនៃការផ្ទុះក្នុងអំឡុងពេលមានអគ្គិភ័យ។ ចំណុចសំខាន់ចំពោះការគ្រប់គ្រងទំនិញនេះដោយសុវត្ថិភាព គឺត្រូវញែកអាម៉ូញូមនីត្រាតចេញពីប្រភពដែលមានកំដៅ និងកន្លែងកខ្វក់។ អាម៉ូញ៉ូមនីត្រាតត្រូវតែដឹកជញ្ជូនចេញភ្លាមៗពីចំណតផែ បន្ទាប់ពីបានលើកចេញពីនាវានិងមិនត្រូវបានឱ្យរក្សាទុកនៅលើចំណតផែ ក.ស.ភ. ឡើយ។

## ៦.៨. ការបណ្តុះបណ្តាលបុគ្គលិក ក.ស.ភ.

គ្រប់បុគ្គលិក ក.ស.ភ. ទាំងអស់ដែលពាក់ព័ន្ធទៅនឹងការដឹកជញ្ជូន និង/ឬលើកដាក់ទំនិញគ្រោះថ្នាក់នៅក្នុងបរិវេណ ក.ស.ភ. ចាំបាច់ត្រូវមានការបណ្តុះបណ្តាលអំពីទំនិញគ្រោះថ្នាក់។

## ៦.៩. ផែនការឆ្លើយតបទៅនឹងគ្រោះអាសន្ននៅក.ស.ភ.

យោងសៀវភៅណែនាំស្តីពីការត្រៀមឆ្លើយតបទៅនឹងគ្រោះអាសន្ន ដែលបានរៀបចំឡើងដោយ ក.ស.ភ. ក្នុងខែធ្នូ ឆ្នាំ២០១៦ បុគ្គលិក ក.ស.ភ.ទាំងអស់ត្រូវយកចិត្តទុកដាក់ក្នុងអនុវត្ត និងត្រៀមលក្ខណៈជានិច្ចសម្រាប់ការឆ្លើយតបទៅនឹងគ្រោះអាសន្នដែលបង្កឡើង ដោយការផ្ទុះឬឆេះនៃប្រតិបត្តិការដឹកជញ្ជូន ផ្ទេរផ្ទុក ឬរក្សាទុកនូវទំនិញគ្រោះថ្នាក់។បន្ថែមពីលើនេះ នៅលើនាវាដែលមានការផ្ទុក ឬលើកទំនិញគ្រោះថ្នាក់ចេញ ត្រូវមានផែនការឆ្លើយតបទៅនឹងគ្រោះអាសន្នពាក់ព័ន្ធទៅនឹងការផ្ទេរផ្ទុកទំនិញគ្រោះថ្នាក់។ ក្នុងករណីមានការកំពប់ ឬហៀរ ត្រូវមានធុងឬឧបករណ៍សម្រាប់ត្រង ជៀសវាងការកំពប់ឬហៀរចូលក្នុងទន្លេ ឬនៅលើទីលាន។

## ៦.៨.១ រចនាសម្ព័ន្ធគ្រប់គ្រងគ្រោះអាសន្ន




## ៧. សន្និដ្ឋាន

កំពង់ផែស្វយ័តភ្នំពេញ មានជំនឿយ៉ាងមុតមាំថា កម្មសិទ្ធិករនាវា/ម្ចាស់ទំនិញ/ភ្នាក់ងារនាវានិងបុគ្គលិក ក.ស.ភ. ទាំងអស់នឹងចូលរួមសហការក្នុងការទប់ស្កាត់ហានិភ័យនានា ដែលបង្កឡើងដោយទំនិញគ្រោះថ្នាក់ ។

គោលការណ៍ណែនាំស្តីពីការគ្រប់គ្រងទំនិញគ្រោះថ្នាក់នៅកំពង់ផែស្វយ័តភ្នំពេញនេះ នឹងត្រូវអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

## ៨. ឧបសម្ព័ន្ធ

### ឧបសម្ព័ន្ធទី១៖ ក្រមទំនិញគ្រោះថ្នាក់តាមសមុទ្រអន្តរជាតិ
### International Maritime Dangerous Goods Code (IMDG Code)

# ប្រភេទចំណាត់ថ្នាក់នៃទំនិញគ្រោះថ្នាក់

| ចំណាត់ថ្នាក់ ១៖ គ្រឿងផ្ទុះ | |
|---|---|
| ឧទាហរណ៍៖ គ្រឿងផ្ទុះ គ្រប់ប្រភេទនៃគ្រាប់រំសេវ យុទ្ធភ័ណ្ឌយោធា កាំជ្រួច និងប្រភេទសារធាតុផ្ទុះ ក្នុងវិស័យឧស្សាហកម្ម។ |  |
| **ចំណាត់ថ្នាក់រង ១.១ ៖** សារធាតុ និងមុខទំនិញដែលមានហានិភ័យបង្កការផ្ទុះ ទ្រង់ទ្រាយធំ ។<br>**ចំណាត់ថ្នាក់រង ១.២ ៖** សារធាតុ និងមុខទំនិញដែលទំនងជាមានហានិភ័យបង្កការផ្ទុះ តែមិនអាចកើតក្នុងទ្រង់ទ្រាយធំ ។<br>**ចំណាត់ថ្នាក់រង ១.៣ ៖** សារធាតុ និងមុខទំនិញដែលអាចបង្កអគ្គីភ័យ តាមរយៈការផ្ទុះ ទ្រង់ទ្រាយតូច ឬអាចមានហានិភ័យ ប៉ុន្តែមិនអាចកើតក្នុងទ្រង់ទ្រាយធំ។<br>**ចំណាត់ថ្នាក់រង ១.៤៖** សារធាតុ និងមុខទំនិញដែលមិនមានហានិភ័យទ្រង់ទ្រាយធំ។<br>**ចំណាត់ថ្នាក់រង ១.៥៖**សារធាតុដែលងាយនឹងបង្កការផ្ទុះបំផុត ហើយអាចកើតក្នុងទ្រង់ទ្រាយធំ។<br>**ចំណាត់ថ្នាក់រង ១.៦៖** សារធាតុដែលងាយនឹងបង្កការផ្ទុះខ្លាំងបំផុត តែមិនអាចកើតក្នុងទ្រង់ទ្រាយធំ។ |  |

<table>
<tr><td colspan="2"><u>ចំណាត់ថ្នាក់ ២ : ឧស្ម័ន</u></td></tr>
<tr><td>
</td><td>
</td></tr>
<tr><td><u>ចំណាត់ថ្នាក់រង ២.១ : ឧស្ម័នឆេះ</u><br><br>ឧស្ម័ន LPG និងឧស្ម័នធម្មជាតិ LNG មានដូចជា ឧស្ម័នដែលបញ្ចូលក្នុងដែកកេះ ឧស្ម័នដែលសម្រាប់បញ្ចូលក្នុងបំពង់ផ្សេងៗ ឧស្ម័នអាសេទីឡែន ប្រើសម្រាប់ការងារផ្សារ ឬលាយលោហៈធាតុចូលគ្នា ឧស្ម័នអេទីឡែន ប្រើសម្រាប់ធ្វើឱ្យផ្លែឈើឆាប់ទុំ និងឧស្ម័នអ៊ីដ្រូសែនប្រើនៅតាមមហាវិទ្យាល័យ និងក្នុងវិស័យឧស្សាហកម្ម ។</td><td>
</td></tr>
<tr><td><u>ចំណាត់ថ្នាក់រង ២.២</u><br><br>ឧស្ម័នដែលមិនអាចឆេះ និងពុំមានជាតិពុល។<br><br>ឧស្ម័នកាបូនិច ដែលមានប្រើនៅក្នុងឧបករណ៍សម្រាប់សំអាតទឹក ចំរាញ់ទឹក ដើម្បីផលិតទឹកក្រូច ឧស្ម័នអុកស៊ីសែន ដែលប្រើ នៅមន្ទីរពេទ្យ នៅរោងជាងផ្សារដែក។</td><td>


</td></tr>
</table>

<table>
<tr><td><u>ចំណាត់ថ្នាក់រង ២.៣ ៖ ឧស្ម័នពុល</u><br><br>ឧស្ម័នមេទីលប្រូមីដ និងឧស្ម័នអេទីឡែនអុកស៊ីត សម្រាប់បំពុលសត្វល្អិត ឧស្ម័ន ក្លរីន សម្រាប់សំអាតទឹក នៅតាមអាងហែលទឹក និងឧស្ម័នអាម៉ូញាក់ សម្រាប់ឧស្សាហកម្មត្លាសេ។</td><td>


</td></tr>
<tr><td colspan="2"><u>ចំណាត់ថ្នាក់ ៣៖ អង្គធាតុរាវងាយឆេះ</u></td></tr>
<tr><td>ប្រេងសាំង ប្រេងកាត ប្រេងដែលមិនមាន សារធាតុសំណ អង្គធាតុរាវអាសេតូន ថ្នាំលាបស្រោបផ្ទៃវត្ថុផ្នែកខាងក្រៅ ថ្នាំលាបដែកឡាន ថ្នាំលាបឱ្យផ្ទៃវត្ថុភ្លឺចែងចាំង អង្គធាតុរាវ មេតា ណុល។</td><td>
</td></tr>
<tr><td colspan="2"><u>ចំណាត់ថ្នាក់ ៤ ៖ អង្គធាតុរឹងងាយឆេះ</u></td></tr>
<tr><td><u>ចំណាត់ថ្នាក់រង ៤.១ ៖ អង្គធាតុរឹងងាយឆេះ</u><br><br>សារធាតុដែលមានប្រតិកម្មដោយឯកឯង និងអង្គធាតុរឹងផ្ទុះកម្រិតមធ្យម។</td><td>
</td></tr>
<tr><td><u>ចំណាត់ថ្នាក់រង ៤.២ ៖ សារធាតុដែលអាចបង្កចំហេះដោយឯកឯង</u><br><br>ឧទាហរណ៍ ៖ កាកសំណល់ត្រី សំឡី ក្រណាត់ប្រើសម្រាប់ជូតគ្រឿងម៉ាស៊ីនរួចហើយ និងសារធាតុហ្វូសផរ</td><td>
</td></tr>
</table>

| | |
|---|---|
| **ចំណាត់ថ្នាក់រង ៤.៣ ៖ សារធាតុដែលប៉ះទឹកបង្កឧស្ម័នចំហេះ**<br>*ឧទាហរណ៍៖* លោហៈធាតុសូដ្យូម ប៉ូតាស្យូម និងកាល់ស្យូមកាបៃ CaC2 (អាសេទីឡែន រលាយ ពេលប៉ះជាមួយទឹក)។ |  |
| **ចំណាត់ថ្នាក់ ៥ ៖ សារធាតុអុកស៊ីត និងសរីរាង្គពែរអុកស៊ីត** | |
| **ចំណាត់ថ្នាក់រង ៥.១ ៖ សារធាតុអុកស៊ីត**<br>*ឧទាហរណ៍* ៖ កាល់ស្យូម Hypochlorite (ថ្នាំក្លរ៉ ដាក់ក្នុងអាងហែលទឹក ដើម្បីសំលាប់មេរោគ) ថ្នាំលាងសំអាតឱ្យស ប្រើនៅតាមផ្ទះ ម្សៅ លាងសំអាត ឬសម្រាប់ហាងបោកគក់ ពពួក អ៊ីដ្រូសែន ប្រើសម្រាប់សំអាតអាងហែលទឹក និង ប្រភេទជីអាម៉ូញ៉ូមនីត្រាត និងសារធាតុជម្រះឱ្យស។ |  |
| **ចំណាត់ថ្នាក់រង ៥.២ ៖ សរីរាង្គពែរអុកស៊ីត**<br>*ឧទាហរណ៍៖* ផលិតផល Plastibond សម្រាប់បិតប៉ះផ្ទៃវត្ថុ ដែលប្រេះស្រាំ ប្រហោង Bondofill<br>សម្រាប់ ការជួសជុលបិតប៉ះឈើ ឬប្រើប្រាស់នៅគ្លីនិកធ្មេញ និងវត្ថុរាវគ្មានពណ៌ ម្យ៉ាងដែលហៅថាម៉េក (MEKP ។ |  |
| **ចំណាត់ថ្នាក់ ៦៖ សារធាតុពុល និងសារធាតុឆ្លង** | |
| **ចំណាត់ថ្នាក់រង ៦.១ : សារធាតុពុល**<br>ឧទាហរណ៍៖ ពពួកថ្នាំសំលាប់សត្វល្អិត ដូចជា ថ្នាំសំលាប់សត្វល្អិតក្នុងវិស័យកសិកម្ម សឹងតែទាំងអស់ និងថ្នាំកំចាត់ស្មៅ និងផលិតផល |  |

| | |
|---|---|
| ឧស្សាហកម្ម ដូចជា ម្សៅសូដ្យូម cyanide ពណ៌ស សម្រាប់ការពារលោហ: និងល្បាយសារធាតុទង់ដែង និងក្រូម សម្រាប់រក្សាផលិតផលឈើឱ្យបានយូរ។ | |
| **ចំណាត់ថ្នាក់រង ៦.២ ៖ សារធាតុឆ្លង**<br><br>*ឧទាហរណ៍ ៖* សំណាកឈាម របស់មនុស្ស ដែលមានផ្ទុកមេរោគ សំណល់ធម្មជាតិពីមនុស្ស និងសំណល់វេជ្ជសាស្ត្រ។ |  |
| **ចំណាត់ថ្នាក់ ៧ ៖ គ្រឿងវិទ្យុសកម្ម** | |
| *ឧទាហរណ៍ ៖* សារធាតុគីមីឈ្មោះកូបាល (Cobalt) អ៊ុយរ៉ានីញ៉ូម និងសារធាតុវិទ្យុសកម្មដទៃទៀត ដែលប្រើនៅមន្ទីរពេទ្យជាផលិតផលសម្រាប់សំលាប់មេរោគ និងសម្រាប់ព្យាបាលជំងឺមហារីក ចំរាញ់ជាតិនុយក្លេអ៊ែរ និងផលិតផលពេទ្យដែលមានប្រើជាតិវិទ្យុសកម្ម ។ |  |
| **ចំណាត់ថ្នាក់ ៨ ៖ សារធាតុច្រេះស៊ី ឬកាត់ (អាស៊ីត)** | |
| *ឧទាហរណ៍៖* អាគុយរថយន្តតូចធំ អាស៊ីតគ្លេស្យាល់អាសេទិក ដែលគេប្រើសម្រាប់បន្ទុំផ្លែឈើ ទឹកសូដ្យូមអុកស៊ីត អាស៊ីត ផ្សេងៗដូចជា ហាដ្រូក្លរិក សុលហ្វ៊ូរិក នីទ្រិក ដែលប្រើនៅក្នុងដំណើរការឧស្សាហកម្ម។ |  |

| **<u>ចំណាត់ថ្នាក់ ៩ ៖ សារធាតុទំនិញគ្រោះថ្នាក់ប្រភេទផ្សេងៗទៀត</u>** | |
|---|---|
| *ឧទាហរណ៍៖* ដុំកាបូនឌីអុកស៊ីតសារធាតុប្រើសម្រាប់ធ្វើឱ្យត្រជាក់ សារធាតុប្រើសម្រាប់ទប់ស្កាត់អគ្គិភ័យហៅថាអាសបេតូស (asbestos ជ័រអ៊ុតផ្ទល់កៅស៊ូ ថ្មទូរស័ព្ទដៃ និងអាគុយកុំព្យូទ័រ។ |  |

# ឧបសម្ព័ន្ធទី២៖ IMO Dangerous Goods Manifest

## IMO DANGEROUS GOODS MANIFEST

(IMO FAL Form 7)

(As required by SOLAS 74, chapter VII, regulations 4.5 and 7-2.2, MARPOL 73/78, Annex III, regulation 4.3 and chapter 5.4, paragraph 5.4.3.1 of the IMDG Code)

| | |
|---|---|
| | Page Number |

| | | |
|---|---|---|
| 1.1 Name of ship | 1.2 IMO number | 1.3 Call sign |

| | | | |
|---|---|---|---|
| 1.4 Voyage number | 2. Flag State of ship | 3. Port of loading | 4. Port of discharge |

| 5. Booking/ Reference Number | 6. Marks & Numbers Container Id No(s). Vehicle Reg. No(s). | 7. Number and kind of packages | 8. Proper Shipping Name | 9. Class | 10. UN No. | 11. Packing Group | 12. Subsidiary Risk(s) | 13. Flashpoint (in °C. c.c.) | 14. Marine Pollutant | 15. Mass (kg) Gross/Net | 16. Ems | 17. Stowage position on board |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | | | | | |
| | | | | | | | | | | | | |
| | | | | | | | | | | | | |
| | | | | | | | | | | | | |
| | | | | | | | | | | | | |

| |
|---|
| Additional information |

| | |
|---|---|
| 18.1 Name of master | 19.1 Shipping Agent |
| 18.2 Place and date | 19.2 Place and date |
| Signature of master | Signature of Agent |

Activ

## ឧបសម្ព័ន្ធទី៣៖ ការគ្រប់គ្រងទូទៅចំពោះការរក្សាទុកនិងផ្ទេរផ្ទុកទំនិញគ្រោះថ្នាក់

| ខ្យល់អាកាសចេញចូល |
|---|
| ខ្យល់អាកាសចេញចូលត្រូវមានគ្រប់គ្រាន់សម្រាប់ការរក្សាទុកទំនិញគ្រោះថ្នាក់ជាកញ្ចប់និងនៅលើទីលាន |
| ខ្យល់អាកាសចេញចូលត្រូវមានគ្រប់គ្រាន់ដោយអាស្រ័យទៅលើកត្តាធម្មជាតិនិងកាលៈទេសៈនៅទីនោះ |
| **ការសង្គ្រោះបឋម** |
| កំពង់ផែស្វយ័តភ្នំពេញត្រូវមានបន្ទប់សង្គ្រោះរួមទាំងថ្នាំពេទ្យសម្រាប់ការសង្គ្រោះបឋម និងមានឧបករណ៍ការពាររាងកាយផ្ទាល់(PPE)។ |
| **សន្តិសុខ និងការចេញចូល** |
| តំបន់ដាក់ទំនិញគ្រោះថ្នាក់ត្រូវមានរបងការពារ ដើម្បីទប់ទល់ទៅនឹងការចូលរបស់បុគ្គលណាមួយដោយគ្មានការអនុញ្ញាត |
| រាល់មធ្យោបាយនៃការចូលនិងចេញពីតំបន់គ្រោះថ្នាក់ ត្រូវមានភាពងាយមើលឃើញគ្រប់ពេលវេលា |
| គ្រប់ពេលវេលាដែលចូលទៅកាន់តំបន់គ្រោះថ្នាក់ត្រូវមាន៖<br>✓ បំពង់ពន្លត់អគ្គិភ័យ<br>✓ ឧបករណ៍ការពាររាងកាយផ្ទាល់ខ្លួន<br>✓ ឧបករណ៍ឬសម្ភារសម្រាប់សម្អាត<br>✓ ទីតាំងដែលទុកប្រតិវេទន៍ទំនិញគ្រោះថ្នាក់<br>✓ តម្លើងកាមេរ៉ាសុវត្ថិភាព |
| **ទំនាក់ទំនង** |
| ដើម្បីឆ្លើយតបទៅនឹងគ្រោះអាសន្ន សូមទំនាក់ទំនងលេខទូរស័ព្ទលេខ ០១០ ៨៨៨ ០៨៨/០១០ ៨៨៨ ០៥១ |
| **ភ្លើងបំភ្លឺ** |
| ត្រូវមានភ្លើងបំភ្លឺគ្រប់គ្រាន់នៅក្នុងតំបន់រក្សាទុកឬលើកដាក់ទំនិញគ្រោះថ្នាក់ |
| **លក្ខខណ្ឌក្នុងគ្រាមានអាសន្ន** |
| ត្រូវមានបណ្តាញទឹកគ្រប់គ្រាន់ដែលស្ថិតនៅជិតសម្រាប់ប្រើប្រាស់ក្នុងគ្រាមានអាសន្ន |
| ត្រូវមានបំពង់ពន្លត់អគ្គិភ័យ ដោយបំពង់ទាំងនោះត្រូវស្ថិតនៅកន្លែងដែលអាចចូលយកបានភ្លាមៗក្នុងគ្រាមានអាសន្ន |

| |
|---|
| ទំនិញគ្រោះថ្នាក់អាចបង្កជាអគ្គីភ័យមានដូចខាងក្រោមៈ<br>✓ ទំនិញគ្រោះថ្នាក់ទាំងនោះអាចបញ្ចេញនូវចំហាយផ្សេង ដែលងាយឆាបឆេះ មានជាតិពុល ឬច្រេះស៊ី ឬងាយឆាបឆេះនៅក្នុងខ្យល់<br>✓ ងាយឆាបឆេះ ឬទំនិញគ្រោះថ្នាក់ជាអុកស៊ីត ដែលអាចបង្កើនប្រតិកម្មឬរាលដាលខ្លាំងក្នុងអគ្គីភ័យ<br>✓ កំពប់ហៀរនូវសារធាតុ និងកម្ទេចកខ្វក់ដែលអាចមានជាតិពុលនៅក្នុងបរិស្ថាន<br>✓ កុងតឺន័រធ្លាយដោយសារការប៉ះទង្គិច ឬបាញ់ចេញនៅពេលមានកំដៅ<br>✓ សារធាតុខ្លះអាចមានប្រតិកម្មយ៉ាងសាហាវជាមួយទឹក ឬមានប្រតិកម្មគីមីផ្សេងទៀត ដែលជាហេតុនាំឱ្យមានបាញ់ធ្លាយទៅលើទីលំហ<br>✓ ការកំពប់លាយចូលគ្នា ឬមានអគ្គីភ័យដោយពុំស្គាល់សារធាតុច្បាស់លាស់<br>✓ ទឹកកខ្វក់ដែលហូរចេញពីកន្លែងមានអគ្គីភ័យ ដែលអាចបង្កគ្រោះថ្នាក់ដល់បុគ្គលិកនិងបរិស្ថាន |
| កុងតឺន័រ |
| ទំនិញក្នុងកុងតឺន័រមិនត្រូវផ្ទេរទៅកាន់កុងតឺន័រណាមួយផ្សេងទៀត សម្រាប់ការរក្សាទុកឡើយ លុះត្រាតែកុងតឺន័រចុងក្រោយនោះសមស្របសម្រាប់ការរក្សាទុកនូវទំនិញគ្រោះថ្នាក់ដ៏ពិសេសនេះ ហើយត្រូវបានសម្គាល់យ៉ាងច្បាស់ជាមួយនឹងផ្លាកសញ្ញាគ្រោះថ្នាក់ដ៏សមស្រប ដើម្បីបង្ហាញអំពីអត្តសញ្ញាណ និងសក្តានុពលគ្រោះថ្នាក់នៃសារធាតុនោះ។ |
| កុងតឺន័រៈ<br>✓ ត្រូវរក្សាទុកនៅទីកន្លែងដែលគ្មានការឆាបឆេះ និងគ្មានការប៉ះទង្គិច ឬខូចផ្នែកខាងក្នុង ប្រសិនបើមានការកំពប់ធ្លាយ<br>✓ ត្រូវរក្សាទុកយ៉ាងហោចណាស់ ៣ម៉ែត្រពីប្រភពកំដៅ<br>✓ ត្រូវបើកនៅលើទីវាលដែលមានខ្យល់អាកាសបក់ចេញចូលសមស្រប<br>✓ ត្រូវបិទទ្វារឱ្យបានសមស្របនៅពេលមិនប្រើប្រាស់<br>✓ មិនត្រូវរក្សាទុកនៅជិតសម្ភារដែលមានប្រតិកម្មឡើយ |
| កុងតឺន័រត្រូវបិទទ្វារជាប្រចាំនៅពេលមិនប្រើប្រាស់ |
| កុងតឺន័រដែលមានទំនិញគ្រោះថ្នាក់ងាយឆាបឆេះ ត្រូវរក្សាទុកឱ្យឆ្ងាយពីប្រភពដែលអាចឆេះដោយឯកឯង |
| ត្រូវមានវិធានការទប់ស្កាត់ចំពោះការកំពប់ហៀរ ក្នុងករណីមានការបើកកុងតឺន័រសម្រាប់ការផ្ទេរបរិមាណនៅក្នុងកុងតឺន័រនោះទៅកាន់កុងតឺន័រមួយទៀត |
| ការផ្ទេរទំនិញគ្រោះថ្នាក់ពីកន្លែងរក្សាទុកទៅកាន់ទីកន្លែងប្រើប្រាស់មួយទៀតត្រូវអនុវត្តឱ្យបានចំពោះការកាត់បន្ថយនូវភាពកំពប់ហៀរ |

| ការរក្សាទុកនិងការដាក់ដាច់ដោយឡែក |
|---|
| ចំពោះសារធាតុដែលមិនត្រូវគ្នា ឬអាចមានប្រតិកម្មក្នុងពេលដាក់លាយជាមួយគ្នា ត្រូវរំលែកទុកដាក់ដាច់ដោយឡែក ដើម្បីកាត់បន្ថយនូវប្រតិកម្ម។ |

# ឧបសម្ព័ន្ធទី៩៖ សេចក្តីជូនដំណឹងស្តីពីការស្តុកទុកកុងតឺន័រផ្ទុកទំនិញគ្រោះថ្នាក់នៅចំណតផែកុងតឺន័រ LM១៧

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**កំពង់ផែស្វយ័តភ្នំពេញ**

លេខ: ..០០៧/១៨....ក.ស.ភ.

ថ្ងៃពុធ ៩កើត ខែបុស្ស ឆ្នាំរកា ព.ស.២៥៦១

រាជធានីភ្នំពេញ, ថ្ងៃទី ១០ ខែមករា គ.ស.២០១៨

## សេចក្តីជូនដំណឹង
## ស្តីពី
## ការស្តុកទុកកុងតឺន័រផ្ទុកទំនិញគ្រោះថ្នាក់នៅចំណតផែកុងតឺន័រ LM១៧

**កំពង់ផែស្វយ័តភ្នំពេញ** (ក. ស. ភ.) មានកិត្តិយសសូមជម្រាបជូនដំណឹងដល់អតិថិជន ដែលជាក្រុមហ៊ុននាវា និងក្រុមហ៊ុនដឹកជញ្ជូនទាំងអស់មេត្តាជ្រាបថា ដើម្បីធានាសុវត្ថិភាពលើការងារប្រតិបត្តិការលើកដាក់ និងរក្សាទុកទំនិញគ្រោះថ្នាក់នៅក្នុងបរិវេណចំណតផែកុងតឺន័រ LM១៧ ក. ស. ភ. បានរៀបចំទីលានសមស្របមួយដាច់ដោយឡែក ដើម្បីធ្វើការគ្រប់គ្រង និងរក្សាទុកទំនិញគ្រោះថ្នាក់ទាំងនោះ។ ដូចនេះ ដើម្បីជួយសម្រួលដល់ការអនុវត្តការងារខាងលើឲ្យមានប្រសិទ្ធភាព ក. ស. ភ. តម្រូវឲ្យលោក លោកស្រី ភាគីក្រុមហ៊ុននាវា និងក្រុមហ៊ុនដឹកជញ្ជូនមេត្តាជួយផ្តល់ព័ត៌មាន ស្តីពី ទំនិញគ្រោះថ្នាក់តាមទំរង់ **IMO FAL Form 7** (ដូចបានភ្ជាប់ជូន) ឲ្យបាន២៤ម៉ោងមុនពេលនាវាមកដល់ (សម្រាប់ការនាំចូល) និង២៤ម៉ោងមុនពេលកុងតឺន័រដឹកជញ្ជូនចូលមកដល់ទីលានរបស់ ក. ស. ភ. (សម្រាប់ការនាំចេញ) ជូនមក ក. ស. ភ. តាមរយៈអ៊ីម៉ែល "**dangerousgoods-ops@ppap.com.kh**"។

សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនងមកកាន់៖

| | | |
|---|---|---|
| ១.លោក **អ៊ឹង ឆាយងួន** | ប្រធានអង្គភាពរៀបចំប្រតិបត្តិការ LM១៧ | លេខទូរស័ព្ទ៖ ០១០ ៨៨៨ ៣៩៨ |
| ២.លោក **លឹម វឌ្ឍនា** | ប្រធានអង្គភាពរៀបវេនប្រតិបត្តិការ LM១៧ | លេខទូរស័ព្ទ៖ ០១០ ៨៨៨ ៣៨៩ |
| ៣.លោក **អ៊ិង សុភ័ក្ត្រ** | អនុប្រធានអង្គភាពរៀបចំប្រតិបត្តិការ LM១៧ | លេខទូរស័ព្ទ៖ ០១០ ៨៨៨ ៦៩៧ |

ក្នុងករណីខកខានពុំបានជូនដំណឹងមក ក. ស. ភ. ជាមុននូវព័ត៌មានស្តីពីទំនិញគ្រោះថ្នាក់ នោះភាគីក្រុមហ៊ុននាវា និងក្រុមហ៊ុនដឹកជញ្ជូន ត្រូវទទួលខុសត្រូវចំពោះមុខច្បាប់នូវរាល់ករណីគ្រោះថ្នាក់ និងខូចខាតទាំងឡាយណាដែលបង្កដោយទំនិញនោះ។

**សេចក្តីជូនដំណឹងនេះ ចាប់អនុវត្តពីថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៨ តទៅ។**

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមអតិថិជនទាំងអស់ មេត្តាជ្រាបជាព័ត៌មាន និងចូលរួមសហការអនុវត្តឲ្យមានប្រសិទ្ធភាពខ្ពស់។

**ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជា**
**ប្រធានអគ្គនាយក**

**ហ៊ី-ប៊ាវី**

ទីស្នាក់ការកណ្តាល: អគារលេខ ៦៤៩ តិវិថីព្រះស៊ីសុវត្ថិ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ទូរស័ព្ទ/ទូរសារ (៨៥៥) ២៣ ៤២៧ ៨០២ Email: ppapmpwt@online.com.kh / info@ppap.com.kh

**KINGDOM OF CAMBODIA**

**Nation Religion King**

**Phnom Penh Autonomous Port**

Nº: ....007/18........PPAP

PHNOM PENH, Date: January 10, 2018

**Announcement**

**on**

**Containers Loaded with Dangerous Goods at Container Terminal LM17**

Phnom Penh Autonomous Port (PPAP) would like to inform all the barge operators and the shipping line companies that in order to ensure the safety of handling and storage of the dangerous-goods containers at Container Terminal LM17, PPAP has set up a separate area to store those containers. Therefore, to ensure an effective implementation, PPAP requires all barge operators and shipping line companies to provide advanced information about dangerous goods at least 24hrs before the arrival of the barge/vessel (for import) and 24hrs before the container arrives at the port (for export) in the format of **IMO FAL Form 7** (as per attachment) to PPAP via this email address **"dangerousgoods-ops@ppap.com.kh"**.

For more information, please kindly contact the following officers:

| | | | |
|---|---|---|---|
| 1. | **Mr. Ung Chhay Ngoun** | Manager of Terminal Planning Unit LM17 | Tel: 010 444 398 |
| 2. | **Mr. Lim Voitana** | Manager of Operation Shift Unit LM17 | Tel: 010 444 389 |
| 3. | **Mr. Ung Sopheak** | Deputy Manager of Terminal Planning Unit LM17 | Tel: 010 444 697 |

**In the case that the barge operators or the shipping line companies fail to send prior information about the dangerous goods to PPAP as required, the barge operators or the shipping line companies shall be liable for all damages and costs caused by the said dangerous goods.**

This announcement is effective from **the 15th of January, 2018 onwards.**

Please all the valued customers be informed and cooperate effectively.

Sincerely yours,

**Bavy HEI**
**Delegate of Royal Government**
**in charge as Chairman & CEO**

Head Office: # 649, Preah Sisowath Quay, Sangkat Sras Chork, Khan Daun Penh, Phnom Penh Fax/Phone: (855) 23 427 802, Email: ppapmpwt@online.com.kh / info@ppap.com.kh

# ឧបសម្ព័ន្ធទី៥៖ វិធានការណ៍បង្កា និងពន្លត់អគ្គិភ័យ

## វិធានការណ៍ បង្ការ និងពន្លត់អគ្គីភ័យ

**សេចក្តីអធិប្បាយ:**

១- **ភ្លើង**គឺជាមធ្យោបាយ បំរើជីវភាពរស់នៅរបស់មនុស្សប្រចាំថ្ងៃជាប្រចាំនៅក្នុងសង្គម ។ តែ**ភ្លើង**នេះវានិងក្លាយទៅជា **អគ្គីភ័យ**ឆេះបំផ្លាញទ្រព្យសម្បត្តិ អាយុជីវិត មនុស្ស សត្វ និងរុក្ខជាតិបានគ្រប់ពេលវេលានៅពេលណាដែលមនុស្សយើងអតនោម័តធ្វេសប្រហែសបាត់ការប្រុងប្រយ័ត្ន។

ដូចនេះប្រជាពលរដ្ឋគ្រប់រូប មានកាតព្វកិច្ច ត្រូវតែចូលរួមក្នុងការងារ**បង្ការ** និង**ពន្លត់អគ្គីភ័យ** ដើម្បីធានាកាត់បន្ថយការឆេះ ខូចខាតទ្រព្យសម្បត្តិ និងអាយុជីវិតមនុស្ស ។

២- **មូលហេតុដែលបង្កឲ្យមានអគ្គីភ័យ:**

-កើតឡើងដោយសារ ការធ្វេសប្រហែសរបស់មនុស្ស (មនុស្សប្រុស ស្រី កូនក្មេង) ដូចជាដុតធូប, ជក់បារី, **ភ្លើង** ទៀន, ដុតផាវ, ដុតវន្ធកណ្ដុរ.................

- កើតឡើងដោយធម្មជាតិ: បន្ទុះភ្នំ **ភ្លើង** រន្ទះបាញ់ ភ្លៀង ខ្យល់ព្យុះ.............

៣- **សញ្ញាណនៃចំហេះ៖** យ៉ាងដូចម្តេចដែលហៅ **ចំហេះ** ? គឺជាប្រតិកម្មគីមី បញ្ចេញកំដៅ និងមានពន្លឺ រឺជាការរួមផ្សំ រវាង **អុកស៊ីហ្សែន ប្រភពកំដៅ** និង **សារធាតុឆេះ**

- កត្តាចាំបាច់ ដែលបណ្តាលឲ្យ**ឆេះ** មាន៣ កត្តាជាចាំបាច់រួមមាន:

ទី១- ប្រភពអុកស៊ីហ្សែន




ទី២- ប្រភពកំដៅ

ទី៣-ជាតិឆេះ

+ **ប្រភពអុកស៊ីហ្សែន:**តម្រូវការអុកស៊ីហ្សែនចាប់ពី ១៦ % ទៅ ២១ %ដែលជាមូលហេតុយ៉ាងសំខាន់ សម្រាប់កើតមាននូវចំហេះ ។

+**ប្រភពកម្តៅ:**

- **សារធាតុគីមី:**ប៉ូលតាស្យូម, សូដយ៉ូម, ម៉ាញ៉េស្យូម,ផូស្វ័រ,ថ្មស្កុយ,អាសុិដស៊ុលផួរីដ,ហ៊ីដ្រូក្លរិចអាស៊ីដ,ហ៊ីដ្រូស៊ីដ,កាល់ស្យូមកាប៊ីត,ប្រូប៉ាន,អាម៉ូនីញ៉ូមនីត្រាត។

-**ចលកនៃមេកានិក:**ប៉ះកកិត, ការឆាបដែក, ការប៉ះទង្គិច បង្កជាផ្កាភ្លើង។

-**ចរន្តអគ្គីសនី:** ខ្សែភ្លើងរលាត់, ឆ្លងចរន្ត, រេស៊ីស្តង់ប្រើហួសកម្លាំងវ៉ាត់ហាមពល។

- **កំដៅផ្ទាល់ ឬចំ:**អណ្តាតភ្លើង, ងងើកភ្លើង,ផ្ការភ្លើងអគ្គីសនី,ការដុត,ការអុជ,ដែកកេះ, ឈើគូស,ភ្លើងទានធូបសីតុណ្ហភាពកើនឡើង,ពន្លឺព្រះអាទិត្យ និង ថាមពលនុយក្លេអ៊ែរ។

+**ជាតិឆេះ**

- **មានរឹង:** (ឈើ, កៅស៊ូ, ប្លាស្ទីក, ក្រដាស់,..................................................................)
- **អង្គធាតុរាវ:** (ប្រេងឥន្ធនៈគ្រប់ប្រភេទ, អាលកុល, ស្រា...............................................)
- **ឧស្ម័ន:** (អាសេទីឡែន, អ៊ីដ្រូហ្សែន, អាម៉ូនីញាក់.......................................................)

**៤- ប្រភេទនៃភ្លើងឬចំហេះ**

**ភ្លើង**ឬ**ចំហេះ**ត្រូវបានបែងចែកជា ៨ ប្រភេទរួមមាន:

ទី១- **ភ្លើង** ប្រភេទA ឆេះចេញពីឈើ ក្រដាស ក្រណាត់ និងជ័រប្លាស្ទិក ។

ទី២- **ភ្លើង**ប្រភេទB ឆេះចេញពី ប្រេងឥន្ធនៈគ្រប់ប្រភេទ និងខ្លាញ់ ស្រា គ្រឿងពន្រាវ។ល។

ទី៣- **ភ្លើង** ប្រភេទC ឆេះចេញពី ចរន្តអគ្គីសនី និងឧស្ម័នឆេះ ។

ទី៤- **ភ្លើង** ប្រភេទ D ឆេះចេញពី លោហៈ ម៉ាញ៉េស្យូម ទីតានីញ៉ូម ស៊ីនកូនីញ៉ូម សូដយ៉ូម ប៉ូតាស្យូម លីជូម កាល់ស្យូម និងស៊ីន ។ ល ។

**៥- បំពង់ពន្លត់អគ្គីភ័យ:**

បំពង់ពន្លត់**អគ្គីភ័យ**មាន ២ ខ្នាត:

- ខ្នាតតូចយួរដោយដៃ មានទម្ងន់ពី ១ ទៅ ១២ គីឡូក្រាម និងខ្នាតធំ មានទម្ងន់ពី ២៥ ទៅ ១៦០ គីឡូក្រាម ដោយភ្ជាប់ដោយកង់អាចរុញអាចចល័តបាន ។
- **ប្រភេទបំពង់ពន្លត់អគ្គីភ័យ:**

រួមមាន: ប្រភេទ AB, BC ,ABC, $CO_2$, FOAM, HALON D, PYROGEN



## **វិធីពន្លត់អគ្គីភ័យ**

វិធីដែលប្រើជាសកលក្នុងការពន្លត់**អគ្គីភ័យ**គឺការធ្វើឲ្យត្រជាក់ឬការដកយកជាតិ**ឆេះ**ចេញពីកន្លែងដែលកំពុង**ឆេះ****ទឹក**មានសីតុណ្ហភាពត្រជាក់គ្រប់គ្រាន់អាចបន្ថយសីតុណ្ហភាពកំដៅនៃ**ភ្លើង**ដែលកំពុងឆេះទៅរកចំណុចមួយដែលជាតិ**ឆេះ**ពុំអាចបញ្ចេញចំហាយ**ឆេះ**ឲ្យបានគ្រប់គ្រាន់ដើម្បីទ្រទ្រង់ការ**ឆេះភ្លើង**រលត់។ កំដៅរបស់**ភ្លើង**អាចនាំទៅរកការឆេះនៅកន្លែងផ្សេងៗបានដោយសារសាយភាយឬការជះរបស់វាការចម្លងដោយកាំរស្មីពន្លឺដោយប៉ះផ្ទាល់ការចម្លងតាមរយៈលោហៈការចម្លងដោយការប្រមូលផ្តុំនៃកំដៅឡើងទៅលើ។**ទឹក**មានលទ្ធភាពអាចស្រូបយក**កំដៅ**បានល្អជាងជាតិពន្លត់ផ្សេងៗ ពេលខ្លះតម្រូវយក**ទឹក**ចាក់ចូលទៅក្នុង**ភ្លើងឆេះ**ផ្ទាល់ដើម្បីតម្រូវឲ្យមានការត្រជាក់គ្រប់គ្រាន់ក្នុងការពន្លត់ ។

- ការដកយកជាតិ**ឆេះ**ចេញដើម្បីឲ្យ**ភ្លើង**រលត់ វាជាករណីមួយដែលមានប្រសិទ្ធភាពបំផុតក៏ប៉ុន្តែវាពុំមានលទ្ធភាពអាចអនុវត្តបានគ្រប់ពេលនោះទេ។

**<u>ឧទាហរណ៍:</u>**ជាច្រើនត្រូវបានយកមកអនុវត្តក្នុងការពន្លត់ដូចជា ការបូមឬបង្ហូរសារធាតុរាវងាយ**ឆេះ**ចេញពីធុងឬស៊ីទែនដែលកំពុង**ឆេះ**ចេញឬការ ប្រមូលយកជាតិ**ឆេះ**ជាសារធាតុរឹងមួយចំណែកណាដែលពុំទាន់**ឆេះ**យកទៅទុកនៅកន្លែងសុវត្ថិភាពមួយការកាត់ផ្តាច់ឬបិទប្រភពឧស្ម័ន**ឆេះ** គឺអាចអនុវត្តបានដោយបិទវ៉ានប្រភពម្យ៉ាងវិញទៀតការដកយកជាតិ**ឆេះ**ចេញដើម្បីឲ្យ**ភ្លើង**រលត់ យើងក៏អាចសម្រេចអនុវត្តបានដោយការពង្រាវល្បាយនៃជាតិ**ឆេះ**នោះ ការពង្រាវនេះ**ទឹក**អាចយកមកពង្រាវបានតែជាមួយអេទីលអាល់កុលឬស្កុរតែប៉ុណ្ណោះព្រោះវាអាចរលាយជាមួយ**ទឹក**ចំពោះសារធាតុរាវងាយឆេះដែលពុំអាចពង្រាវល្បាយបានជាមួយ**ទឹក**នោះគឺយើងអាចពង្រាវបានដោយបញ្ចូលជាតិ តេលូតកា (Emulsifying)ជាតិពន្លត់ពិសេសនេះ វាអាចកកខះ អណ្តែតនៅលើផ្ទៃមុខនៃសារធាតុរាវងាយ**ឆេះ** បញ្ឈប់សកម្មភាពចំហាយ**ឆេះ**ដែលសាយភាយចេញពីសារធាតុរាវងាយ**ឆេះ**នោះ ។ ម្យ៉ាងវិញទៀតនៅក្នុងលំហរឧស្ម័នងាយ**ឆេះ**យើងក៏អាចពង្រាវល្បាយវាបានដែរ ដោយយើងបញ្ចូលបន្ថែមនៅក្នុងឧស្ម័នងាយ**ឆេះ**នោះនូវ ឧស្ម័ន អ៊ីណឺត ដូចជាការបោនម៉ូណូស៊ីត ឬនីត្រូសែន ។

ការពន្លត់**ភ្លើង**ដែល**ឆេះ**តូចតាច ដោយការកាត់ផ្តាច់ប្រភពអុកស៊ីហ្សែន

**<u>ឧទាហរណ៍:</u>**ការឆេះខ្លាញ់ឬប្រេងឆានៅក្នុងខ្ទះចៀនក្នុងករណីនេះ យើងអាចយកគម្របខ្ទះនោះមកគ្របឬយកបន្ទះអ្វីមកគ្របឲ្យជិតនៅលើខ្ទះចៀននោះ ដើម្បីកាត់ផ្តាច់ប្រភពអុកស៊ីហ្សែននោះ**ភ្លើង**អាចរលត់បានភ្លាមតែនេះជាវិធីតូចៗងាយស្រួលតែប៉ុណ្ណោះ។ក្នុងករណីមួយចំនួនទៀត យើងពុំអាចពន្លត់**ភ្លើង**បានដោយប្រើវិធីតូចតាច ឬងាយស្រួលសាមញ្ញ ដូចបានពោលមកខាងលើនោះឡើយ

**<u>ឧទាហរណ៍:</u>**ការ**ឆេះ**ប្លាស្ទិកដូចជាស៊ីលុយលូសនីត្រាតឬ**ឆេះ**លោហៈគឺតម្រូវឲ្យយើងរកវិធីផ្សេងទៀតមកពន្លត់ ។

ការស្រាវជ្រាវអំពីរបៀប**ឆេះ**របស់**ភ្លើង**ជាច្រើន បានបង្ហាញអំពីប្រតិកម្មគីមីជាបន្តបន្ទាប់នៃការឆេះរបស់**ភ្លើង**អ្នកពន្លត់បានរកឃើញនូវគំនិតពន្លត់**ភ្លើង**ថ្មីទៀតដោយទទួលបាននូវលិទ្ធផលល្អប្រសើរ

ជាងមុនក្នុងការពន្លត់។ដោយបានរកឃើញនូវជាតិពន្លត់ថ្មី ដោយការលាយបញ្ចូលគ្នានូវអាតូមប្រើដោយចរន្តអគ្គីសនី ដែលមានលទ្ធភាពស្រូបបឺតយកកំដៅនិងមានលទ្ធភាពបន្ថយឬបញ្ឈប់សកម្មភាពប្រតិកម្មគីមីជាបន្ត
បន្ទាប់របស់ភ្លើង ដែលជាលទ្ធផលអាចរលត់ភ្លើងបានយ៉ាងល្អប្រសើរ ។

## **វិធីពន្លត់អគ្គីភ័យដោយប្រើបំពង់ពន្លត់**

១- យកបំពង់ពន្លត់មកកាន់នៅក្នុងដៃក្រឡុកចុះក្រឡុកឡើង ។
២- ដាក់បំពង់ចុះដៃម្ខាងទប់កបំពង់ដកក្រវិលចេញ ។
៣-កាន់គល់មាត់ត្រែទុយោតម្រង់ទៅភ្លើងក្នុងចម្ងាយ២មឬ២,៥០ម
 រួចច្របាច់ស្លាបព្រាបំពង់ចុះដើម្បីឲ្យជាតិពន្លត់ចេញទៅពន្លត់ ភ្លើង ។
៤- វេទុយោចុះឡើងដើម្បីឲ្យ ភ្លើង រលត់បានល្អ ។



## ៦- តារាងប្រសិទ្ធភាពបំពង់ពន្លត់**អគ្គីភ័យ:**

| ល.រ | សារធាតុ ឬអង្គធាតុឆេះ | ប្រសិទ្ធភាពប្រើប្រាស់ | | | | | | |
|---|---|---|---|---|---|---|---|---|
| | | $CO_2$ | BC | ABC | D | M | FOAM | HALON |
| A | ចំហេះឈើ, ក្រដាស, ប្លាស្ទិច..... | | | 🔥 | | | 🔥 | 🔥 |
| B | ចំហេះប្រេងឥន្ធនៈ......... | 🔥 | 🔥 | 🔥 | | | 🔥 | 🔥 |
| C | ចំហេះហ្គាស................ | 🔥 | 🔥 | 🔥 | | | | 🔥 |
| D | ចំហេះលោហៈធាតុ........ | 🔥 | | | 🔥 | | 🔥 | 🔥 |
| E | ចរន្តអគ្គិសនី.................. | 🔥 | 🔥 | 🔥 | | | | 🔥 |
| M | ចំហេះកង់យន្តហោះ.......... | | | | | 🔥 | | |

## ៧- វិធីសាស្ត្រក្នុងការពន្លត់**អគ្គីភ័យ:**

ការពន្លត់**អគ្គីភ័យ**មាន ៤ ប្រភេទ:

ទី១- ពន្លត់ដោយបន្ថយ សីតុណ្ហភាព (ការធ្វើឲ្យត្រជាក់)

ទី២- ពន្លត់ដោយកាត់ផ្ដាច់ប្រភពជាតិឆេះ (បិទវ៉ាន ឬ ដកយកចេញ)

ទី៣- ពន្លត់ដោយកាត់ផ្ដាច់ប្រភពអុកស៊ីហ្សែន (គ្រប ឬបិទឲ្យជិត)

ទី៤- ពន្លត់ដោយបញ្ឈប់ប្រតិកម្មជាបន្តរបន្ទាប់នៃសារធាតុគីមី (ពង្រាវ ឬ បន្សាបល្បាយធាតុគីមី)



## របៀបជំលៀសខ្លួនចេញពីតំបន់មានអគ្គីភ័យ

- នៅពេលចេញពីអាគារដែលមានភ្លើងឆេះ ត្រូវលុតជង្គង់ចុះដើរ ដោយប្រើខ្នងដៃស្ទាបកំដៅលើទ្វារ ឬជញ្ជាំង ប្រសិនបើក្តៅ មានន័យថាម្ខាងទៀតក៏មាន ភ្លើង ឆេះដែរ។



## របៀបពន្លត់ភ្លើងឆេះសំលៀកបំពាក់

- ប្រសិនបើ ភ្លើង ឆេះសំលៀកបំពាក់របស់អ្នក ត្រូវឈប់ យកដៃបិទមុខ ក្រាបចុះ ហើយរមៀល ដើម្បីពន្លត់អណ្តាត ភ្លើង ឆេះ ។




## របៀបសង្គ្រោះជនរងគ្រោះក្នុងអគ្គីភ័យ





# ឧបសម្ព័ន្ធទី៦៖ អនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០២០ ស្តីពីការដាក់ឱ្យប្រើប្រាស់បញ្ជីទំនិញហាមឃាត់ និងទំនិញជាប់កម្រិតកំណត់

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ...១៧....អនក្រ.បក

**អនុក្រឹត្យ**

**ស្តីពី**

**ការដាក់ឱ្យប្រើប្រាស់បញ្ជីទំនិញហាមឃាត់ និងទំនិញជាប់កម្រិតកំណត់**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៧/០១៧ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីគយ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧១៩/១០២៤ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០១៩ ស្តីពីការបង្កើតគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី ២៥ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការកែសម្រួលអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី០១ ខែមីនា ឆ្នាំ២០០៦ ស្តីពីកិច្ចសម្រួលពាណិជ្ជកម្មតាមរយៈការគ្រប់គ្រងហានិភ័យ

១

- បានឃើញអនុក្រឹត្យលេខ ២០៩ អនក្រ.បក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៧ ស្តីពី ការដាក់ឱ្យប្រើប្រាស់បញ្ជីទំនិញហាមឃាត់ និងទំនិញជាប់កម្រិតកំណត់
- បានឃើញអនុក្រឹត្យលេខ ២០៨ អនក្រ.បក ចុះថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០១១ ស្តីពីការកែសម្រួលលើកំណត់សម្គាល់II នៃឧបសម្ព័ន្ធ២ នៃអនុក្រឹត្យលេខ២០៩ អនក្រ.បក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៧ ស្តីពីការដាក់ឱ្យប្រើប្រាស់បញ្ជីទំនិញហាមឃាត់និងទំនិញជាប់កម្រិតកំណត់
- យោងតាមសំណើរបស់ប្រធានគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

**មាត្រា ១.-**

ត្រូវបានដាក់ឱ្យប្រើប្រាស់បញ្ជីទំនិញហាមឃាត់និងទំនិញជាប់កម្រិតកំណត់ តាមតារាងពន្ធគយកម្ពុជាឆ្នាំ២០១៧ ជាធរមាន ដូចមានចែងក្នុងឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

**មាត្រា ២.-**

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវធ្វើបច្ចុប្បន្នភាពលេខកូដទំនិញ ក្នុងបញ្ជីជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះឱ្យបានទាន់ពេលវេលា ស្របតាមការផ្លាស់ប្តូរប្រព័ន្ធសុខដុមនីយកម្មរបស់អង្គការគយពិភពលោក (WCO HS) និងការផ្លាស់ប្តូរនាមវលីនៃតារាងពន្ធគយស៊ីចង្វាក់របស់អាស៊ាន (AHTN)។

**មាត្រា ៣.-**

មុខទំនិញជាកម្មវត្ថុនៃការហាមឃាត់ ឬជាប់កម្រិតកំណត់លើការនាំចេញ នាំចូល និងការដឹកជញ្ជូនឆ្លងកាត់ ត្រូវបានកំណត់ក្នុងអនុក្រឹត្យនេះ។ ការកែសម្រួលមុខទំនិញ និង/ឬ ប្រព្រឹត្តកម្មនៃទំនិញហាមឃាត់និងទំនិញជាប់កម្រិតកំណត់ ត្រូវធ្វើឡើងក្នុងក្របខណ្ឌគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា ៤.-**

ក្នុងករណីមានហានិភ័យដែលតម្រូវឱ្យមានចំណាត់ការបន្ទាន់ជាយថាហេតុ ក្រសួងមានសមត្ថកិច្ចពាក់ព័ន្ធអាចដាក់វិធានការជាបណ្តោះអាសន្នក្នុងការគ្រប់គ្រងការនាំចេញ នាំចូល ឬការឆ្លងកាត់នៃមុខទំនិញដែលមានហានិភ័យ ទោះបីពុំមានចែងក្នុងអនុក្រឹត្យនេះក៏ដោយ និងត្រូវបញ្ជាក់ឱ្យបានច្បាស់លាស់នូវរយៈពេលនៃការអនុវត្តវិធានការទាំងនោះ ដោយមិនឱ្យលើសពី ០៦ ខែ។ វិធានការបណ្តោះអាសន្នទាំងនោះ អាចត្រូវបញ្ចប់មុនកាលកំណត់ ឬពន្យារពេល តាមស្ថានភាពជាក់ស្តែង។

**មាត្រា ៥.-**

អនុក្រឹត្យលេខ ២០៩ អនក្រ.បក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៧ ស្តីពី ការដាក់ឱ្យប្រើប្រាស់បញ្ជីទំនិញហាមឃាត់ និងទំនិញជាប់កម្រិតកំណត់ និងអនុក្រឹត្យលេខ ២០៨ អនក្រ.បក ចុះថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០១១ ស្តីពីការកែសម្រួលលើកំណត់សម្គាល់II នៃឧបសម្ព័ន្ធ២ នៃអនុក្រឹត្យលេខ២០៩ អនក្រ.បក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៧ និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៦.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃទី០១ ខែមេសា ឆ្នាំ២០២០ តទៅ។

ថ្ងៃ ពុធ ៤ កើត ខែ ផល្គុន ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ ២០២០

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី សូមឡាយព្រះហស្តលេខា

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

***កន្លែងទទួល៖***

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៦
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# បញ្ជីទំនិញហាមឃាត់

## ឧបសម្ព័ន្ធ ១

នៃអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ២០២០

### បញ្ជីទំនិញហាមឃាត់

| ល.រ | លេខកូដ | បរិយាយមុខទំនិញ | MOH | MOE | MOI |
|---|---|---|---|---|---|
| 1 | 2620.11.00 | -- កាកស័ង្កសីចូង | | (3) | |
| 2 | 2620.19.00 | -- ផ្សេងទៀត | | (3) | |
| 3 | 2620.21.00 | -- កករកាវប្រេងសាំងកេតជាតិសំណនៃសមាសធាតុជំនួយចំហេះ ដែលមានសំណ | | (3) | |
| 4 | 2620.29.00 | -- ផ្សេងទៀត | | (3) | |
| 5 | 2620.30.00 | - ដែលមានភាគច្រើនជាទង់ដែង | | (3) | |
| 6 | 2620.40.00 | - ដែលមានភាគច្រើនជាអាលុយមីញ៉ូម | | (3) | |
| 7 | 2620.60.00 | - ដែលមាន អាសេនិក បារត តាល្យូម ឬល្បាយរបស់វា នៃប្រភេទប្រើប្រាស់សម្រាប់ទាញយកអាសេនិក ឬលោហៈទាំងនោះ ឬសម្រាប់ផលិតកម្ម នៃ សមាសធាតុគីមីរបស់វា | | (3) | |
| 8 | 2620.91.00 | -- ដែលមាន អង់ទីម៉ូនី បេរីល្យូម កាដ្មីញ៉ូម ក្រូមីញ៉ូម ឬល្បាយរបស់វា | | (3) | |
| 9 | 2620.99.10 | --- អាចម៍លោហៈ និងសំណល់រឹងនៃសំណធាតុហ្សាំង | | (3) | |
| 10 | 2620.99.90 | --- ផ្សេងទៀត | | (3) | |
| 11 | 2621.10.00 | - ផេះ និង សំណល់ បានពីការដុតកាកសំណល់តាមទីក្រុង | | (3) | |
| 12 | 3006.92.10 | --- ឱសថ សម្រាប់ព្យាបាលរោគមហារីក រោគអេដស៍/ហ៊ីវ ឬ រោគពិបាកព្យាបាលផ្សេងទៀត | (4) | | |
| 13 | 3604.90.20 | -- រំសេវជាតិផ្ទុះ និងជាវសម្រាប់ក្មេងលេង | | | (4) |
| 14 | 3824.71.90 | --- ផ្សេងទៀត | | (3) | |
| 15 | 3825.10.00 | - សំណល់ពីទីក្រុង | | (3) | |
| 16 | 3825.20.00 | - ភក់ល្យ | | (3) | |
| 17 | 3825.30.10 | -- សឺរ៉ាំង មូល បំពង់សុល និងវត្ថុប្រហាក់ប្រហែល | | (3) | |
| 18 | 3825.30.90 | -- ផ្សេងទៀត | | (3) | |

| ល.រ | លេខកូដ | បរិយាយមុខទំនិញ | MOH | MOE | MOI |
|---|---|---|---|---|---|
| 19 | 3825.41.00 | - - ផ្សំជាមួយអាឡូសែន | | (3) | |
| 20 | 3825.49.00 | - - ផ្សេងទៀត | | (3) | |
| 21 | 3825.50.00 | - សំណល់នៃសូលុយស្យុងសម្រាប់ព្រំលោហធាតុ ពីប្រេងអ៊ីដ្រូលិក ពីប្រេងហ្វ្រាំង និង ថ្នាំការពារការឡើងកក | | (3) | |
| 22 | 3825.61.00 | - - ផ្សំឡើងដោយគីមីសរីរាង្គ | | (3) | |
| 23 | 3825.69.00 | - - ផ្សេងទៀត | | (3) | |
| 24 | 3825.90.00 | - ផ្សេងទៀត | | (3) | |
| 25 | 3915.20.10 | - - ធ្វើពីផលិតផល សែលុយឡូ មិនរឹង | | (3) | |
| 26 | 3915.20.90 | - - ផ្សេងទៀត | | (3) | |
| 27 | 3915.30.10 | - - ធ្វើពីផលិតផល សែលុយឡូ មិនរឹង | | (3) | |
| 28 | 3915.30.90 | - - ផ្សេងទៀត | | (3) | |
| 29 | 3915.90.00 | - ធ្វើពីប្លាស្ទិកផ្សេងទៀត | | (3) | |
| 30 | 4707.90.00 | - ផ្សេងទៀត រាប់បញ្ចូលទាំងសំណល់ និងកម្ទេចកម្ទី មិនទាន់ជ្រើស | | (3) | |
| 31 | 7001.00.00 | អំបែងកែវ និង សំណល់ និងកម្ទេចកែវផ្សេងទៀត; កែវទាំងដុល | | (3) | |
| 32 | 7503.00.00 | កាកសំណល់ និងកម្ទេចនីកែល | | (3) | |
| 33 | 7802.00.00 | កាកសំណល់ និងកម្ទេចសំណ | | (3) | |
| 34 | 8002.00.00 | កាកសំណល់ និងកម្ទេចសំណប៉ាហាំង | | (3) | |
| 35 | 8102.97.00 | - - កាកសំណល់ និងកម្ទេច | | (3) | |
| 36 | 8103.30.00 | - កាកសំណល់ និងកម្ទេច | | (3) | |
| 37 | 8104.20.00 | - កាកសំណល់ និងកម្ទេច | | (3) | |
| 38 | 8105.30.00 | - កាកសំណល់ និងកម្ទេច | | (3) | |
| 39 | 8106.00.10 | - ប៊ីស្មុតមិនទាន់ច្នៃ; កាកសំណល់និងកម្ទេច; ម្សៅ | | (3) | |
| 40 | 8107.30.00 | - កាកសំណល់ និងកម្ទេច | | (3) | |
| 41 | 8108.30.00 | - កាកសំណល់ និងកម្ទេច | | (3) | |

| លរ | លេខកូដ | បរិយាយមុខទំនិញ | MOH | MOE | MOI |
|---|---|---|---|---|---|
| 42 | 8109.30.00 | - កាកសំណល់ និងកម្ទេច | | (3) | |
| 43 | 8110.20.00 | - កាកសំណល់ និងកម្ទេច | | (3) | |
| 44 | 8111.00.10 | - កាកសំណល់ និងកម្ទេច | | (3) | |
| 45 | 8111.00.90 | - ផ្សេងទៀត | | (3) | |
| 46 | 8112.13.00 | - - កាកសំណល់ និងកម្ទេច | | (3) | |
| 47 | 8112.22.00 | - - កាកសំណល់ និងកម្ទេច | | (3) | |
| 48 | 8112.52.00 | - - កាកសំណល់ និងកម្ទេច | | (3) | |
| 49 | 8112.92.00 | - - មិនទាន់ច្នៃ; កាកសំណល់ និងកម្ទេច; ម្សៅ | | (3) | |
| 50 | 8113.00.00 | លោហៈសេរ៉ាមិច និងវត្ថុធ្វើពីវា, រាប់បញ្ចូលទាំងកាកសំណល់ និងកម្ទេច ។ | | (3) | |
| 51 | 8548.10.13 | - - - ឧបករណ៍ផ្ទុកថាមពលអគ្គិសនី (សាកបាន) ដែលមានតង់ស្យុង ៦V និង ១២V ដែលមានកម្ពស់ (មិនរាប់បញ្ចូលក្បាលចាប់ និងដៃយួរ) មិនលើសពី ២៣ cm | | (3) | |
| 52 | 8548.10.19 | - - - ផ្សេងទៀត | | (3) | |
| 53 | 8548.10.20 | - - កាកសំណល់ និងកម្ទេច ដែលភាគច្រើនជាដែក | | (3) | |
| 54 | 8548.10.30 | - - កាកសំណល់ និងកម្ទេច ដែលភាគច្រើនជាទង់ដែង | | (3) | |
| 55 | 8548.10.91 | - - - នៃថ្មពិលមិនអាចសាកបាន | | (3) | |
| 56 | 8548.10.92 | - - - នៃឧបករណ៍ផ្ទុកថាមពលអគ្គិសនី (សាកបាន) ជាប្រភេទប្រើក្នុងយន្តហោះ | | (3) | |
| 57 | 8548.10.99 | - - - ផ្សេងទៀត | | (3) | |

## ឯកសារយោង


១. ព្រះរាជក្រម នស/រកម/០១០៦/០០៥ ស្ដីពីការប្រកាសឱ្យប្រើ ច្បាប់ស្ដីពីការអនុម័តយល់ព្រមលើពិធីសារទី៩ ស្ដីពីទំនិញគ្រោះថ្នាក់

២. អនុក្រឹត្យលេខ១៧ អនក្របក ស្ដីពីការដាក់ឱ្យប្រើប្រាស់បញ្ជីទំនិញហាមឃាត់ និងទំនិញជាប់កម្រិតកំណត់

៣. គោលការណ៍ណែនាំស្ដីពីការរក្សាទុក ផ្ទេរផ្ទុកទំនិញគ្រោះថ្នាក់ រៀបចំឡើងសម្រាប់កំពង់ផែ/ចំណតផែក្នុងប្រទេសកម្ពុជា និងវៀតណាម

៤. Dangerous goods manifest, IMO FAL Form 7

៥. ក្រមទំនិញគ្រោះថ្នាក់តាមសមុទ្រអន្តរជាតិ IMDG Code

៦. Procedure to handle Dangerous Goods at Laem Chabang Port

៧. Standard operating procedure for dangerous cargo handling Johor Port Berhad (Malaysia)